ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រដ្ឋបាលជលផល

# ការធ្វើជំរឿននិងផ្តល់ស្លាកលេខ
# បណ្តោះអាសន្នដល់នាវានេសាទសមុទ្រនៅខេត្តតំបន់ឆ្នេរ
# នៃព្រះរាជាណាចក្រកម្ពុជា




ខែសីហា ឆ្នាំ២០២០

**អារម្ភកថា**..........vii
**សេចក្តីសង្ខេប**..........viii
**ជំពូកទី១. សេចក្តីផ្តើម**..........១
១.១. សាវតារ..........២
១.២. ការធ្វើជំរឿននិងការផ្តល់ស្លាកលេខបណ្តោះអាសន្ន..........៣
១.២.១. ការប្រមូលព័ត៌មាន..........៣
១.២.២. ក្រុមការងារធ្វើជំរឿននិងផ្តល់ស្លាកលេខបណ្តោះអាសន្ន..........៣
១.៣. ការរៀបចំបញ្ជីសំណួរនិងឯកសារពាក់ព័ន្ធនិងការផ្តល់ប័ណ្ណសម្គាល់និងការបំពាក់ស្លាកលេខបណ្តោះអាសន្ន៤
១.៣.១. ការរៀបចំបញ្ជីសំណួរនិងឯកសារពាក់ព័ន្ធ..........៤
១.៣.២. ការផ្តល់ប័ណ្ណសម្គាល់និងការបំពាក់ស្លាកលេខបណ្តោះអាសន្ន..........៤
១.៤. ការជ្រើសរើសនិងការបណ្តុះបណ្តាលមន្ត្រីធ្វើជំរឿន..........៦
១.៥. ការរៀបចំផ្សព្វផ្សាយនិងការងាររដ្ឋបាល មុននឹងចាប់ផ្តើមអនុវត្តការងារជំរឿន..........៨
១.៥.១. ការរៀបចំផ្សព្វផ្សាយមុននឹងចាប់ផ្តើមអនុវត្តការងារជំរឿន..........៨
១.៥.២. ការងាររដ្ឋបាលមុននឹងចាប់ផ្តើមអនុវត្តការងារជំរឿន..........៩
១.៦. ការរក្សា គ្រប់គ្រងនិងវិភាគទិន្នន័យនិងព័ត៌មាននាវានេសាទសមុទ្រ..........១០
**ជំពូកទី ២. លទ្ធផលនៃការធ្វើជំរឿន ផ្តល់ប័ណ្ណសម្គាល់ និងការបំពាក់ស្លាកលេខបណ្តោះអាសន្ន**...១២
២.១. ការវិភាគទិន្នន័យនាវាសមុទ្រសរុបដែលបានធ្វើជំរឿន..........១២
២.២. ការវិភាគទិន្នន័យនាវានេសាទសមុទ្រសរុបដែលបានធ្វើជំរឿន..........១៣
២.២.១. ការធ្វើចំណាត់ថ្នាក់នាវានេសាទសមុទ្រ..........១៣
២.២.២. ឧបករណ៍នេសាទសមុទ្រ..........១៨
២.២.២. លក្ខណៈរូបសាស្ត្ររបស់នាវានេសាទសមុទ្រ..........១៨
២.៣. ចំនួនអ្នកនេសាទពេញម៉ោង..........៣១
២.៤. កន្លែងនេសាទនិងភូមិនេសាទ..........៣២
២.៥. សៀវភៅកត់ត្រាស្ថិតិ..........៣៣
២.៦. ឧបករណ៍អេឡិចត្រូនិកសំខាន់ៗដែលមានប្រើលើនាវានេសាទ..........៣៣
២.៦.១. ឧបករណ៍កំណត់ទីតាំងនិងធ្វើចរាចរនៅលើសមុទ្រ..........៣៣
២.៦.២. ឧបករណ៍ទំនាក់ទំនង..........៣៤
២.៦.៣. ឧបករណ៍សុវត្ថិភាពនៅលើនាវា..........៣៤
២.៦.៤. ឧបករណ៍ស្វែងរកហ្វូងត្រី..........៣៤
២.៧. ការថែរក្សាផលនេសាទ..........៣៤
**ជំពូកទី ៣. ការគ្រប់គ្រងនាវានេសាទ ផែនេសាទ កន្លែងឡើងត្រី និងកន្លែងចតនាវានេសាទ** ៣៥
៣.១. ការចុះបញ្ជីនិងផ្តល់លិខិតអនុញ្ញាតឱ្យធ្វើនេសាទ..........៣៥
៣.២. ការចុះបញ្ជីនិងផ្តល់ស្លាកលេខបណ្តោះអាសន្នពីមុន..........៣៧
៣.៣. ការស្រង់ស្ថិតិផលនេសាទ..........៣៧
៣.៤. ការគ្រប់គ្រងផែនេសាទ កន្លែងឡើងត្រី និងកន្លែងចតនាវានេសាទ..........៣៨
**ជំពូកទី៤. សន្និដ្ឋាននិងអនុសាសន៍**..........៤៤

**បញ្ជីតារាង**

តារាងទី១. ស្ថិតិនាវានេសាទសមុទ្រឆ្នាំ២០១៨ របស់រដ្ឋបាលជលផល
តារាងទី២. ស្លាកលេខសម្គាល់បណ្តោះអាសន្នសម្រាប់ខេត្តតំបន់ឆ្នេរ
តារាងទី៣. ផែនការសកម្មភាព
តារាងទី៤. ចំនួននាវាសមុទ្រដែលបានប្រមូលដោយគម្រោង
តារាងទី៥. ចំនួននាវានេសាទនិងនាវាពាក់ព័ន្ធសរុប
តារាងទី៦. ចំនួននិងប្រភេទនានាសមុទ្រដែលបានធ្វើជំរឿន
តារាងទី៧. ចំនួននាវានេសាទសមុទ្រដែលបានធ្វើជំរឿននៅខេត្តតំបន់ឆ្នេរ
តារាងទី៨. ការចាត់ថ្នាក់នាវានេសាទសមុទ្រជា៣ក្រុមតាមប្រវែងបណ្តោយសរុបនៅខេត្តតំបន់ឆ្នេរ
តារាងទី៩. ការចាត់ថ្នាក់នាវានេសាទសមុទ្រជា៥ក្រុមតាមប្រវែងបណ្តោយសរុបនៅខេត្តតំបន់ឆ្នេរ
តារាងទី១០. នាវានេសាទអួនអូសនិងនាវានេសាទឈ្នាងអូសគ្រែងឈាមដែលមានប្រវែងខ្លីជាង១២ម៉ែត្រ
តារាងទី១១. ការគណនាចំនួននាវានេសាទអួនអូសនិងឈ្នាងអូសគ្រែងឈាមដែលមានប្រវែងខ្លីជាង១២ម៉ែត្រ
តារាងទី១២. ចំនួននាវានេសាទខ្នាតធំ ខ្នាតមធ្យម និងខ្នាតតូចសរុបផ្អែកតាមច្បាប់ថ្មីស្តីពីនាវានេសាទសមុទ្រ
តារាងទី១៣. ការធ្វើចំណាត់ថ្នាក់នាវានេសាទតាមកម្លាំងម៉ាស៊ីន
តារាងទី១៤. ការធ្វើចំណាត់ថ្នាក់នាវានេសាទតាមកម្លាំងម៉ាស៊ីនសម្រាប់ខេត្តតំបន់ឆ្នេរ
តារាងទី១៥. ការបែងចែកនាវានេសាទជា២ថ្នាក់តាមកម្លាំងម៉ាស៊ីន
តារាងទី១៦. ប្រភេទឧបករណ៍នេសាទសមុទ្រចំនួន៣៤ប្រភេទដែលកំពុងមានប្រើនៅក្នុងដែននេសាទសមុទ្រ
តារាងទី១៧ក. ប្រភេទឧបករណ៍នេសាទសមុទ្រទាំងអស់ដែលមានប្រើនៅក្នុងដែននេសាទសមុទ្រ
តារាងទី១៧ខ. ប្រភេទឧបករណ៍នេសាទសមុទ្រទាំងអស់បែងចែកទៅតាមចំណាត់ថ្នាក់នាវានេសាទ
តារាងទី១៨ក. ប្រភេទឧបករណ៍នេសាទសមុទ្រទាំងអស់ដែលមានប្រើនៅខេត្តកោះកុង
តារាងទី១៨ខ. ប្រភេទឧបករណ៍នេសាទសមុទ្រនៅក្នុងខេត្តកោះកុងបែងចែកទៅតាមចំណាត់ថ្នាក់នាវានេសាទ
តារាងទី១៩ក. ប្រភេទឧបករណ៍នេសាទសមុទ្រទាំងអស់ដែលមានប្រើនៅខេត្តព្រះសីហនុ
តារាងទី១៩ខ. ប្រភេទឧបករណ៍នេសាទសមុទ្រនៅក្នុងខេត្តព្រះសីហនុបែងចែកទៅតាមចំណាត់ថ្នាក់នាវានេសាទ
តារាងទី២០ក.ប្រភេទឧបករណ៍នេសាទសមុទ្រទាំងអស់ដែលមានប្រើនៅខេត្តកំពត
តារាងទី២០ខ. ប្រភេទឧបករណ៍នេសាទសមុទ្រនៅក្នុងខេត្តកំពតបែងចែកទៅតាមចំណាត់ថ្នាក់នាវានេសាទ
តារាងទី២១ក.ប្រភេទឧបករណ៍នេសាទសមុទ្រទាំងអស់ដែលមានប្រើនៅខេត្តកែប
តារាងទី២១ខ. ប្រភេទឧបករណ៍នេសាទសមុទ្រនៅក្នុងខេត្តកែបបែងចែកទៅតាមចំណាត់ថ្នាក់នាវានេសាទ
តារាងទី២២. ប្រភេទសំបកនាវានេសាទសមុទ្រ
តារាងទី២៣. ប្រភេទពណ៌នាវានេសាទសមុទ្រ
តារាងទី២៤. ចំនួននាវានេសាទសមុទ្រដែលប្រើម៉ាស៊ីន១និងម៉ាស៊ីន២
តារាងទី២៥. ចំនួននាវានេសាទសមុទ្រដែលប្រើម៉ាស៊ីនម៉ាស៊ូតនិងម៉ាស៊ីនសាំង
តារាងទី២៦. ម៉ាកម៉ាស៊ីនដែលបានប្រើដោយអ្នកនេសាទសមុទ្រ
តារាងទី២៧. ចំនួនអ្នកនេសាទសមុទ្រនៅខេត្តតំបន់ឆ្នេរ
តារាងទី២៨. ការធ្វើចំណាត់ថ្នាក់ចំនួនអ្នកនេសាទក្នុងនាវានេសាទ១គ្រឿងនៅខេត្តតំបន់ឆ្នេរ
តារាងទី២៩. ចំនួនឧបករណ៍ធ្វើចរាចរនៅលើនាវានេសាទសមុទ្រ

តារាងទី៣០. ចំនួនឧបករណ៍ទំនាក់ទំនងនៅលើនាវានេសាទសមុទ្រ
តារាងទី៣១. ចំនួនឧបករណ៍សុវត្ថិភាពនៅលើនាវានេសាទ
តារាងទី៣២. ចំនួនឧបករណ៍ស្វែងរកហ្វូងត្រីនៅលើនាវានេសាទសមុទ្រ
តារាងទី៣៣. វិធីថែរក្សាផលនេសាទនៅលើនាវានេសាទសមុទ្រ
តារាងទី៣៤. ចំនួននាវានេសាទសមុទ្របានចុះបញ្ជី និងមិនបានចុះបញ្ជី
តារាងទី៣៥. ផែនេសាទ កន្លែងឡើងត្រីតាមផែតូចៗ និងកន្លែងឡើងត្រីតាមភូមិនៅខេត្តតំបន់ឆ្នេរ
តារាងទី៣៦ក ទីតាំងផែនេសាទ កន្លែងឡើងត្រី និងភូមិនេសាទនៅខេត្តកោះកុង
តារាងទី៣៦ខ ទីតាំងផែនេសាទ កន្លែងឡើងត្រី និងភូមិនេសាទនៅខេត្តព្រះសីហនុ
តារាងទី៣៦គ ទីតាំងផែនេសាទ កន្លែងឡើងត្រី និងភូមិនេសាទនៅខេត្តកំពត
តារាងទី៣៦ឃ. ទីតាំងផែនេសាទ កន្លែងឡើងត្រី និងភូមិនេសាទនៅខេត្តកែប

**បញ្ជីរូបភាព**


រូបទី១. សកម្មភាពក្រុមតាមដានត្រួតពិនិត្យការធ្វើជំរឿននាវានេសាទសមុទ្រ នៅឃុំត្រពាំងរពៅ ស្រុកទឹកឈូ ខេត្តកំពត

រូបទី២. ប័ណ្ណសម្គាល់នាវានេសាទម៉ាស៊ីនក្នុងមានគ្រែង(ពណ៌ផ្ទៃមេឃ) និងទូកនេសាទម៉ាស៊ីនក្នុង ឬក្រៅគ្មានគ្រែង (ពណ៌លឿង)

រូបទី៣. គំរូស្លាកលេខនាវានេសាទម៉ាស៊ីនក្នុង និងម៉ាស៊ីនក្រៅ

រូបទី៤. វគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តជាក់ស្តែងប្រព័ន្ធទិន្នន័យនៃការចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតសាកល្បង

រូបទី៥. វគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រក្នុងការធ្វើជំរឿននាវានេសាទសមុទ្រ និងការសាកល្បងប្រើបញ្ជីសំណួរ

រូបទី៦. សិក្ខាសាលាថ្នាក់ជាតិស្តីពីការចាប់ផ្តើមដំណើរធ្វើជំរឿននាវានេសាទសមុទ្រនៅក្នុងប្រទេសកម្ពុជា

រូបទី៧. ការជួបប្រជុំជាមួយថ្នាក់ដឹកនាំនៅខេត្តតំបន់ឆ្នេរ

រូបទី៨. កន្លែងនេសាទរបស់អ្នកនេសាទសមុទ្រនៅក្នុងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា

**បញ្ជីក្រាហ្វិក**

ក្រាហ្វិកទី១. នាវានេសាទនិងនាវាពាក់ព័ន្ធនេសាទដែលបានធ្វើជំរឿនគិតជាចំនួន និងគិតជាភាគរយ
ក្រាហ្វិកទី២. នាវានេសាទសមុទ្រសរុប និងនាវានេសាទសមុទ្រតាមបណ្តាខេត្តសមុទ្រទាំង៤ បែងចែកជា៥ ថ្នាក់ តាមប្រវែងបណ្តោយនាវា
ក្រាហ្វិកទី៣. នាវានេសាទសមុទ្រសរុប និងនាវានេសាទសមុទ្រតាមបណ្តាខេត្តសមុទ្រទាំង៤ បែងចែកជា៥ថ្នាក់ តាមកម្លាំងម៉ាស៊ីន
ក្រាហ្វិកទី៤. នាវានេសាទសមុទ្រសរុបបែងចែកជា២ថ្នាក់ តាមកម្លាំងម៉ាស៊ីន
ក្រាហ្វិកទី៥. ទំនាក់ទំនងរវាងប្រវែងនាវានេសាទ និងកម្លាំងម៉ាស៊ីន
ក្រាហ្វិកទី៦កនិង៦ខ. ស្ថានភាពក្នុងការផ្តល់លិខិតអនុញ្ញាតឱ្យដល់នាវានេសាទសមុទ្រ

**បញ្ជីឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធ១. ទីកន្លែងដែលបានធ្វើជំរឿន
ឧបសម្ព័ន្ធ២. ក្រុមការងារ ឈ្មោះមន្ត្រីធ្វើជំរឿននិងមន្ត្រីពាក់ព័ន្ធទាំងអស់

# អារម្ភកថា

វិស័យជលផលនៃប្រទេសកម្ពុជាមានសារៈសំខាន់ណាស់ ចំពោះសុវត្ថិភាពស្បៀង និងជីវភាពរស់នៅរបស់ប្រជាជន។ ផលនេសាទសមុទ្របានកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ បង្កើតការងារ និងសន្តិសុខស្បៀងដល់សហគមន៍តំបន់ឆ្នេរ។ តំបន់ឆ្នេរសមុទ្រដែលសម្បូរទៅដោយទីជម្រកវារីសត្វសំខាន់ៗ ដូចជាព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រដែលមានផលិតភាពខ្ពស់។ បច្ចុប្បន្នតំបន់ឆ្នេរបាននឹងកំពុងរងនូវការគំរាមកំហែង ដោយការនេសាទខុសច្បាប់និងវិធីនេសាទដែលបំផ្លិចបំផ្លាញដូចជាអួនអូស ឈ្នាងអូសគ្រែងឈាម និងលបប្រើស១០០ជាដើម។ ដើម្បីការពារ និងទប់ស្កាត់នូវសកម្មភាពអវិជ្ជមានទាំងនេះ រាជរដ្ឋាភិបាលបានធ្វើការកែទម្រង់នៃការគ្រប់គ្រងធនធានជលផលតាមរយៈការចូលរួមគ្រប់គ្រងដោយសហគមន៍នេសាទ ព្រមទាំងការសហការរវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការការពារទីជម្រក និងតំបន់គ្រប់គ្រងជលផលសមុទ្រ។ ទោះបីវិធានការមួយចំនួនត្រូវបានដាក់ឱ្យអនុវត្តក៏ដោយ ក៏នៅមានភស្តុតាងមួយចំនួនបង្ហាញថា ធនធានជលផលសមុទ្រកំពុងតែរងនូវសម្ពាធខ្លាំងពីការបំផ្លិចបំផ្លាញទីជម្រកសំខាន់ៗ និងការនេសាទហួសកម្រិត។ ទន្ទឹមនេះដែរ ផែនការសកម្មភាពសំខាន់ពីរត្រូវបានរៀបចំឡើងដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់នៅក្នុងដែនសមុទ្រ។ ផែនការសកម្មភាពពីរនោះ រួមមានផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានលិខិតអនុញ្ញាត និងគ្មានរបាយការណ៍ឆ្នាំ២០២០-២០២៤ និងផែនការត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ ឆ្នាំ២០២០-២០២៤។

ការធ្វើជំរឿននាវានេសាទសមុទ្រនេះ គឺជាសកម្មភាពសំខាន់មួយក្នុងផែនការទាំងពីរខាងលើ នោះគឺការរៀបចំការចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតឱ្យធ្វើនេសាទដល់នាវានេសាទសមុទ្រទាំងអស់។ ទន្ទឹមនឹងនេះ មូលដ្ឋានទិន្នន័យគ្រឹះរបស់នាវានេសាទសមុទ្រ នឹងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយរដ្ឋបាលជលផល និងស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រងនាវានេសាទសមុទ្រ។ លើសពីនេះ លទ្ធផលពីការធ្វើជំរឿននាវានេសាទនេះ បានជួយដល់ការធ្វើចំណាត់ថ្នាក់នាវានេសាទតាមច្បាប់ស្តីពីជលផល ស្តង់ដារថ្នាក់តំបន់ និងស្តង់ដារអន្តរជាតិ។

ជាទីបញ្ចប់ខ្ញុំសង្ឃឹមថា លទ្ធផលដែលទទួលបានពីការធ្វើជំរឿននេសាទនេះនឹងជួយរដ្ឋបាលជលផល ក្នុងការគ្រប់គ្រងធនធានជលផលសមុទ្រប្រកបដោយប្រសិទ្ធភាពខ្ពស់ ជាពិសេសគឺកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចុះបញ្ជីនិងផ្តល់លិខិតអនុញ្ញាតឱ្យធ្វើនេសាទដល់នាវានេសាទសមុទ្រទាំងអស់។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋបាលជលផលពាក់ព័ន្ធទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបំពេញការងារនេះ និងសូមថ្លែងអំណរគុណជាពិសេសសហភាពអឺរ៉ុបដែលបានគាំទ្រថវិកា និងជំនួយបច្ចេកទេសក្នុងការអនុវត្តការងារនេះ។

ថ្ងៃចន្ទ ៣រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ២០២០

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**

# សេចក្តីសង្ខេប

ការធ្វើជំរឿននាវានេសាទសមុទ្របានប្រព្រឹត្តទៅចាប់ពីខែមករាដល់ខែធ្នូ ឆ្នាំ២០១៨។ ការរៀបចំផែនការសកម្មភាព ការបណ្តុះបណ្តាលមន្ត្រីធ្វើជំរឿនដែលមានមន្ត្រីជលផលនិងមន្ត្រីសាធារណការនិងដឹកជញ្ជូន និងការផ្សព្វផ្សាយពីការធ្វើជំរឿនដល់មន្ត្រីពាក់ព័ន្ធ ជាពិសេសអាជ្ញាធរដែនដីតាមបណ្តាខេត្តនៅតំបន់ឆ្នេរ គឺចាប់ពីខែមករាដល់ពាក់កណ្តាលខែសីហា។ រយៈពេលនៃការធ្វើជំរឿន គឺពីរខែកន្លះចាប់ពីពាក់កណ្តាលខែសីហាដល់ចុងខែតុលា ឆ្នាំ២០១៨។ មន្ត្រីអនុវត្តកិច្ចការនេះសរុបទាំងអស់មានចំនួន១៦៥នាក់ ក្នុងនោះចែកចេញជា ក្រុមធំចំនួន១៣ក្រុម ក្រុមតូចចំនួន២៩ក្រុម និងក្រុមតាមដានត្រួតពិនិត្យចំនួន១ក្រុម។ នាវានេសាទគ្មានម៉ាស៊ីន មិនត្រូវបានដាក់បញ្ចូលក្នុងការងារជំរឿនទេ។

នាវាសមុទ្រសរុបដែលបានធ្វើជំរឿនមានចំនួន៧ ៨១១គ្រឿង ក្នុងនោះខេត្តកោះកុងមានចំនួន២ ៦២៣គ្រឿង ស្មើនឹង៥២% ខេត្តព្រះសីហនុចំនួន១ ២៦៣គ្រឿង ស្មើនឹង២៥% ខេត្តកំពតចំនួន៦៦១គ្រឿង ស្មើនឹង១៣% និងខេត្តកែបចំនួន៥២៤គ្រឿង ស្មើនឹង១០%។ នាវាសមុទ្រទាំងនេះចែកចេញជា៥ប្រភេទ គឺនាវានេសាទមានចំនួន៧ ៥៥២គ្រឿង ស្មើនឹង៩៧% នាវាដឹកផលនេសាទមានចំនួន១៧១គ្រឿង ស្មើនឹង២% នាវាទិញផលនេសាទមានចំនួន២០គ្រឿង ស្មើនឹង០,៣% នាវាពាក់ព័ន្ធនឹងវារីវប្បកម្មមានចំនួន៣៣គ្រឿង ស្មើនឹង០,៤% និងនាវាផ្សេងៗមានចំនួន៣៥គ្រឿង ស្មើនឹង០,៤%។

នាវានេសាទសរុបមានចំនួន៧ ៥៥២គ្រឿង ក្នុងនោះខេត្តកោះកុងមានចំនួន៣ ៣៩៦គ្រឿង ស្មើនឹង៤៥% ខេត្តព្រះសីហនុមានចំនួន២ ៥២៣គ្រឿង ស្មើនឹង៣៣,៤% ខេត្តកំពតមានចំនួន១០៣៩គ្រឿង ស្មើនឹង១៣,៨% និងខេត្តកែបមានចំនួន៥៩៤គ្រឿង ស្មើនឹង៧,៩%។ នាវានេសាទសមុទ្រមានម៉ាស៊ីនត្រូវបានបែងចែកជាបីចំណាត់ថ្នាក់ តាមប្រវែងនាវានេសាទសរុបនិងប្រភេទឧបករណ៍នេសាទ។ នាវានេសាទខ្នាតធំដែលមានប្រវែងវែងជាង២៤ម៉ែត្រមានចំនួន១០គ្រឿង ស្មើនឹង០,១% នាវានេសាទខ្នាតមធ្យមដែលមានប្រវែងចាប់ពី១២-២៤ម៉ែត្រ និងនាវាអួនអូសនិងនាវាឈ្នាងអូសគ្រែងឈាមខ្លីជាង១២ម៉ែត្រមានចំនួន៣ ៥១២គ្រឿង ស្មើនឹង៤៦,៤% និងខ្នាតតូចដែលមានប្រវែងខ្លីជាង១២ម៉ែត្រមានចំនួន៤ ០៣០គ្រឿង ស្មើនឹង៥៣,៥%។ នាវានេសាទដែលមានកម្លាំងតូចជាង៥០សេះមានចំនួន៦ ៦៩៩គ្រឿង ស្មើនឹង៨៨,៧% នាវានេសាទដែលមានកម្លាំងធំជាង៩០សេះមានចំនួន៥៧៤គ្រឿង ស្មើនឹង៧,៦% និងនាវានេសាទដែលមានកម្លាំងតូចជាង៩០សេះមានចំនួន៦ ៩៧៨គ្រឿង ស្មើនឹង៩២,៤%។

ឧបករណ៍នេសាទសមុទ្រសំខាន់ៗមានចំនួន៣៤ប្រភេទ ដូចជាអួនអូស លបក្តាម មងក្តាម មងត្រី លបប្រឹស ១០០ មងបង្គា សន្ទូចរនងអូសមឹក រនងខ្សែចាប់មឹកពីង៣ង ឈិបយន្ត នេសាទដោយដៃ ឈ្នាងអូសគ្រែងឈាម លបត្រី សន្ទូច អួនកាកឹម លបមឹក ស្ន ផ្ទូងផាង សន្ទូចរនងស្រទាប់បាត មុជជីកគ្រំដីរុំ(អយស្ទ័រ) អួនហ៊ុម មងបង្កង កណ្តូប ទូកភ្លើង លបបង្គា ឈិបអូសគី ឈ្នាងដួសក្តាម សន្ទូចរនងត្រី អួនហោះ(អួនអូសត្រី) សន្ទូចរនងបបែល ស្រទាប់បាត អួនហ៊ុមក្បែរឆ្នេរ អួនទិត មងហ៊ុម ឈ្នាងក្តាម សំណាញ់ និងលបខ្សង។

នាវានេសាទដែលមានសំបកឈើមានចំនួន៦ ៤៩៥គ្រឿង ស្មើនឹង៨៦% និងសំបកស្មាច់មានចំនួន១ ០៥៧ គ្រឿង ស្មើនឹង១៤%។ ជាទូទៅ នាវានេសាទសមុទ្រមានប្រើម៉ាស៊ីន១និងម៉ាស៊ីន២។ នាវានេសាទធំៗប្រើម៉ាស៊ីនតែមួយទេ ជានាវាម៉ាស៊ីនបាត។ នាវានេសាទដែលមានម៉ាស៊ីន២ គឺជានាវានេសាទម៉ាស៊ីនក្រៅ ច្រើនប្រើឧបករណ៍ នេសាទមងត្រី ឬមងបង្គា។ នាវានេសាទម៉ាស៊ីន១មានចំនួន៩៨%។ នាវានេសាទខេត្តព្រះសីហនុមានប្រើ

ម៉ាស៊ីន២ ច្រើនជាងខេត្ត៣ទៀតនៃខេត្តតំបន់ឆ្នេរ។ នាវានេសាទដែលប្រើម៉ាស៊ីនម៉ាស៊ូតមានចំនួន៤ ៥០៣គ្រឿង ស្មើនឹង៦០% និងនាវានេសាទដែលប្រើម៉ាស៊ីនសាំងមានចំនួន៣ ០៤៨គ្រឿង ស្មើនឹង៤០%។ ម៉ាស៊ីននាវានេសាទសមុទ្រមានចំនួន២៧ប្រភេទ។ ម៉ាស៊ីននាវានេសាទសំខាន់ៗមានចំនួន៥ប្រភេទដូចជា យ៉ានដុង (Yandong) និងយ៉ានហ្វា (Yanfa) ផលិតនៅប្រទេសចិន ហុងដា (Honda) និងយ៉ានម៉ា (Yanma) ផលិតនៅប្រទេសជប៉ុន និងហ៊ីយុនដាយ (Hyundai) ផលិតនៅប្រទេសសាធារណរដ្ឋកូរ៉េ។ នាវានេសាទភាគច្រើនផ្តុំគ្នាធ្វើនេសាទនៅតាមតំបន់ឆ្នេរ។ មានតែនាវានេសាទ២១គ្រឿងប៉ុណ្ណោះ មានសៀវភៅកត់ត្រាស្ថិតិផលនេសាទ។

នៅលើនាវានេសាទសមុទ្រមានប្រើឧបករណ៍ជីភីអេស (GPS) ចំនួន២៩% ឧបករណ៍អេកូសោនឌ័រ-ជីភីអេស (Acho Sounder-GPS) ចំនួន១% និងត្រីវិស័យចំនួន១%ដែរ។ នាវានេសាទដែលមិនមានឧបករណ៍កំណត់ទីតាំង និងធ្វើចរាចរមានចំនួន៦៩%។ ឧបករណ៍ទំនាក់ទំនងមាន៣ប្រភេទ គឺទូរស័ព្ទដៃចំនួន៣៩% វិទ្យុទាក់ទង ឬវិទ្យុស្តារចំនួន៤២% និងរ៉ាដាចំនួន១គ្រឿង។ នាវានេសាទគ្មានឧបករណ៍ទំនាក់ទំនងមានចំនួន១៩%។ ឧបករណ៍សុវត្ថិភាពមាន៣ប្រភេទ គឺពីដុងជ័រដាក់ប្រេងចំនួន៣៧% អាវពោងចំនួន៤% និងពោងជ័រចំនួនតែ០,៣%ផងដែរ។ នាវានេសាទគ្មានឧបករណ៍សុវត្ថិភាពមានចំនួន៦០%។ ឧបករណ៍ស្វែងរកហ្វូងត្រីមាន៣ប្រភេទ គឺអេកូសោនឌ័រចំនួន១,៤% អេកូសោនឌ័រ-ជីភីអេសចំនួន២% និងសូណាមានតែ១គ្រឿង។ នាវានេសាទគ្មានឧបករណ៍ស្វែងរកហ្វូងត្រីចំនួន៩៧%។ នាវានេសាទធំៗដូចជានាវាអួនកាកឹម អួនទិត និងនាវាអួនអូសទើបមានបំពាក់ឧបករណ៍ទំនើបៗ និងមានតម្លៃថ្លៃ។ ផលនេសាទត្រូវបានថែរក្សាទុកតាមមធ្យោបាយ៤យ៉ាង គឺការដាក់ក្លាសេទឹកកកមានចំនួន៤៥% ថែរក្សារស់មានចំនួន២៩% ទុកក្នុងម៉ាស៊ីនបង្កកមានចំនួន០,១% និងទុកចោលលើនាវានៅពេលកំពុងនេសាទមានចំនួន២៦%។ នាវានេសាទខ្នាតតូចទាំងអស់និងនាវានេសាទខ្នាតមធ្យមមួយចំនួន ទៅធ្វើនេសាទក្រោម២៤ម៉ោង និងពេលយប់ មិនមានប្រើទឹកកកដើម្បីថែរក្សាគុណភាពត្រីទេ។

នាវានេសាទសមុទ្រចំនួនប្រមាណ៩៧%មិនបានចុះបញ្ជីនាវានេសាទទេ។នាវានេសាទមានលិខិតអនុញ្ញាតឱ្យធ្វើនេសាទចំនួន១១៦គ្រឿង (លិខិតអនុញ្ញាតចេញដោយរដ្ឋបាលជលផលចំនួន៩៦គ្រឿង និងចេញដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន២០គ្រឿង)។ នាវានេសាទសមុទ្រចំនួន២៣៤គ្រឿងបានចុះបញ្ជី ប៉ុន្តែមាននាវានេសាទតែ១១៦គ្រឿងប៉ុណ្ណោះ ដែលបានមកសុំលិខិតអនុញ្ញាតធ្វើនេសាទ។

ផែនេសាទ កន្លែងឡើងត្រីតាមផែតូចៗ និងកន្លែងឡើងត្រីតាមភូមិចំនួន៨១កន្លែងត្រូវបានកំណត់ទីតាំង។ ចំនួនអ្នកនេសាទសមុទ្រសរុបមានចំនួន១៦ ១៥១នាក់ ក្នុងនោះខេត្តកោះកុងចំនួន៧ ២០១នាក់ ខេត្តព្រះសីហនុចំនួន៥ ៦៨៦នាក់ ខេត្តកំពតចំនួន២ ០៤២នាក់ និងខេត្តកែបចំនួន១ ២២២នាក់។

# ជំពូកទី ១
# សេចក្តីផ្តើម

វិស័យជលផលកម្ពុជាបានរួមចំណែកយ៉ាងសំខាន់ដល់ការងារនិងជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ ក៏ដូចជាសន្តិសុខស្បៀង ផលិតផលក្នុងស្រុកសរុប និងតុល្យភាពរូបិយប័ណ្ណបរទេស។ ជលផលសមុទ្របានរួមចំណែកពី ១៤-១៦%នៃផលិតផលជលផលសរុប។ ផលនេសាទសមុទ្រមធ្យមមានប្រមាណ១២០ ០០០តោន/ឆ្នាំ ចាប់ពីឆ្នាំ២០១៥មក។ ផលិតផលជលផលសរុបមានតម្លៃប្រមាណជា២០០-៣០០លានដុល្លារ/ឆ្នាំ។ ការនេសាទ ការកែច្នៃ និងការធ្វើពាណិជ្ជកម្មផលនេសាទសមុទ្របានរួមចំណែកប្រមាណ៨-១២%នៃផលិតផលក្នុងស្រុកសរុប។

ធនធានជលផលសមុទ្រនៃប្រទេសកម្ពុជា ត្រូវបានគំរាមកំហែងដោយការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍(ការនេសាទអាយយូយូ) ដែលកំពុងបង្កជាបញ្ហាធ្ងន់ធ្ងរបំផុតប៉ះពាល់ដល់ការនេសាទក្នុងប្រទេស ក្នុងតំបន់ និងក្នុងពិភពលោក។ ការនេសាទអាយយូយូ មានប្រមាណស្មើរតែ១/៣នៃការនេសាទសរុប។ យោងតាមរបាយការណ៍វាយតម្លៃសមត្ថភាពនេសាទនិងការនេសាទនៅកម្ពុជា បានរកឃើញថាការនេសាទសមុទ្រមានភាពធ្ងន់ធ្ងរហួសកម្រិត (មាននាវានេសាទច្រើនពេកធ្វើនេសាទនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់កម្ពុជា) ដែលបណ្តាលមកពីការនេសាទខុសច្បាប់ដោយនាវានេសាទក្នុងស្រុកនិងនាវានេសាទបរទេស។ នាវានេសាទក្នុងស្រុកភាគច្រើនមិនបានចុះបញ្ជីនិងគ្មានលិខិតអនុញ្ញាតធ្វើនេសាទ។

សកម្មភាពនេសាទអាយយូយូដោយនាវានេសាទបរទេសដែលដាក់ទង់ជាតិកម្ពុជា បានបំពានលើប្រព័ន្ធគ្រប់គ្រងជលផលនៅក្នុងសមុទ្រអន្តរជាតិ ក្នុងតំបន់ដែលគ្រប់គ្រងដោយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់។ អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់បានជូនដំណឹងរដ្ឋាភិបាលកម្ពុជា អំពីសកម្មភាពនេសាទខុសច្បាប់ទាំងនេះច្រើនលើក ប៉ុន្តែមិនមានសកម្មភាពដោះស្រាយ។ នៅទីបំផុត គណៈកម្មការអឺរ៉ុបដាក់កម្ពុជាថាជាប្រទេសទី៣ដែលមិនសហការក្នុងការប្រយុទ្ធប្រឆាំងនឹងការនេសាទអាយយូយូ(កាតក្រហម) និងហាមឃាត់ការនាំចេញផលនេសាទសមុទ្រ ទៅកាន់សហភាពអឺរ៉ុប។ បន្ទាប់មកដើម្បីដោះស្រាយបញ្ហានេះអគ្គលេខាធិការដ្ឋានកិច្ចការដែនសមុទ្រនិងជលផលនៃសហភាពអឺរ៉ុបបានអញ្ជើញក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលជលផលទៅចូលរួមពិភាក្សាដោះស្រាយបញ្ហាខាងលើ។ វិធានការចំនួន៩ចំណុចត្រូវបានព្រមព្រៀងក្នុងនោះការចុះបញ្ជីនាវានេសាទនិងការផ្តល់លិខិតអនុញ្ញាតនេសាទ គឺជាសកម្មភាពអាទិភាពមួយក្នុងចំណោមសកម្មភាពអាទិភាពនានាខាងលើ។ ដើម្បីរៀបចំផែនការ ការចុះបញ្ជីនាវានេសាទ និងការផ្តល់លិខិតអនុញ្ញាតនេសាទឱ្យបានត្រឹមត្រូវ គម្រោងជំរឿននាវានេសាទនិងផ្តល់ស្លាកលេខនាវានេសាទសមុទ្រ ត្រូវបានអនុម័តយល់ព្រមដោយរដ្ឋបាលជលផលនិងតំណាងសហភាពអឺរ៉ុបដែលក្នុងនោះក៏មានការផ្តល់ថវិកាសម្រាប់អនុវត្តគម្រោងនេះផងដែរ។

## ១.១. សាវតារ

កន្លងមកការគ្រប់គ្រងនាវានេសាទសមុទ្រត្រូវបានបែងចែកជារដ្ឋបាលថ្នាក់ជាតិមានសមត្ថកិច្ច (រដ្ឋបាលជលផល) និងរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ច (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងខណ្ឌរដ្ឋបាលជលផល)។ នាវានេសាទគ្មានម៉ាស៊ីននិងនាវានេសាទដែលមានកម្លាំងម៉ាស៊ីនតូចជាង៣៣សេះ ត្រូវបានគ្រប់គ្រងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងនាវានេសាទមានម៉ាស៊ីនធំជាង៣៣សេះ ត្រូវបានគ្រប់គ្រងដោយរដ្ឋបាលថ្នាក់ជាតិមានសមត្ថកិច្ច។

យោងតាមការកែទម្រង់របស់រដ្ឋាភិបាលកម្ពុជា (សេចក្តីសម្រេចស្តីពីការផ្ទេរមុខងារជាក់លាក់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ៣៩សសរ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧) ការគ្រប់គ្រងនាវានេសាទត្រូវបានកែសម្រួលដោយរដ្ឋបាលមានសមត្ថកិច្ចថ្នាក់ជាតិ (រដ្ឋបាលជលផល) គ្រប់គ្រងនាវានេសាទ សមុទ្រដែលមានកម្លាំងធំជាង៥០សេះ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ច(មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងខណ្ឌរដ្ឋបាលជលផល) គ្រប់គ្រងនាវានេសាទដែលមានកម្លាំងតូចជាង៥០សេះវិញ។ នៅរដ្ឋបាលជលផលនិងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងខណ្ឌរដ្ឋបាលជលផល) មិនមានប្រព័ន្ធមូលដ្ឋានទិន្នន័យ ដើម្បីរក្សាទុកទិន្នន័យ និងព័ត៌មាននាវានេសាទទាំងនេះទេ។

យោងតាមការចាំបាច់ និងតាមស្តង់ដារអន្តរជាតិ ការធ្វើចំណាត់ថ្នាក់នាវានេសាទត្រូវបានកំណត់តាមចំណុះនាវានេសាទ ឬតាមប្រវែងបណ្តោយសរុបរបស់វា(ប្រទេសថៃធ្វើចំណាត់ថ្នាក់នាវានេសាទតាមចំណុះផ្ទុក និងប្រទេសវៀតណាមធ្វើចំណាត់ថ្នាក់នាវានេសាទតាមប្រវែងបណ្តោយនាវាសរុប)។

នាវានេសាទសមុទ្រកម្ពុជាត្រូវបានធ្វើចំណាត់ថ្នាក់ជាទូកគ្មានម៉ាស៊ីននិងនាវានេសាទមានម៉ាស៊ីន។ នាវានេសាទមានម៉ាស៊ីនត្រូវបានបែងចែងតាមកម្លាំងសេះដូចខាងក្រោម៖

១. តូចជាង១០សេះ
២. ចាប់ពី១០សេះដល់៣៣សេះ
៣. ចាប់ពី៣៣សេះដល់៥៥សេះ
៤. ធំជាង៥៥សេះ។

របាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលជលផល យោងតាមចំណាត់ថ្នាក់ ដូចមានក្នុងតារាងទី១ខាងក្រោម។

**តារាងទី១. ចំនួននាវានេសាទសមុទ្រ (របាយការណ៍ប្រចាំឆ្នាំ២០១៨របស់រដ្ឋបាលជលផល)**

| ខេត្ត | នាវានេសាទគ្មានម៉ាស៊ីន | នាវានេសាទមានម៉ាស៊ីនគិតតាមកម្លាំងម៉ាស៊ីន (សេះ) | | | | |
|---|---|---|---|---|---|---|
| | | < ១០ | ១១-៣៣ | ៣៤-៥០ | >៥១ | សរុប |
| កោះកុង | ១ | ២០៩៩ | ៤៧៣ | ៨៧ | ១៥៥ | ៧១៥ |
| ព្រះសីហនុ | ៥២០ | ១០៩៥ | ១៣៦០ | ៥ | ២៨៥ | ១៦៥០ |
| កំពត | ២៤២ | ២៦៣ | ១៥៨ | 0 | 0 | ១៥០ |
| កែប | ១៣៤ | ៤៦០ | ៤២ | 0 | 0 | ៤២ |
| **សរុប១** | **៨៩៧** | **៣៩១៧** | **២០៣៣** | **៩២** | **៩២** | **២៥៦៥** |
| **សរុប២** | **៨៩៧** | **៦៤៨២** | | | | |
| **សរុបរួម** | **៧៣៧៩** | | | | | |

គម្រោងធ្វើជំរឿននិងផ្តល់ស្លាកលេខនាវានេសាទសមុទ្រនេះ នឹងជួយរដ្ឋបាលជលផលធ្វើចំណាត់ថ្នាក់នាវានេសាទឡើងវិញស្របតាមស្តង់ដារ ដូចដែលមានចែងនៅក្នុងសេចក្តីព្រាងច្បាប់ថ្មីស្តីពីជលផល។ លើសពីនេះគម្រោងនេះមានគោលដៅសំខាន់ៗមួយចំនួនដូចខាងក្រោម៖

១.បង្កើតប្រព័ន្ធទិន្នន័យនិងព័ត៌មានលម្អិតសម្រាប់នាវានេសាទសមុទ្រទាំងអស់ នៅតាមខេត្តតំបន់ឆ្នេរ ដើម្បីកំណត់សមត្ថភាពនាវានេសាទក្នុងស្រុក សម្រាប់ការតាមដានត្រួតពិនិត្យ និងអង្កេត និងគាំទ្រដល់ការបង្កើតគោលនយោបាយគ្រប់គ្រងនាវានេសាទសមុទ្រ។

២. ប្រមូលទិន្នន័យនិងព័ត៌មាននាវានេសាទទាំងអស់ ដើម្បីជាមូលដ្ឋានក្នុងការចុះបញ្ជីនៅក្រសួងសាធារណការនិងដឹកជញ្ជូន សម្រាប់នាវានេសាទខ្នាតមធ្យមនិងខ្នាតធំនិងការផ្តល់លិខិតអនុញ្ញាតឱ្យប្រើប្រាស់នាវានេសាទ និងធ្វើអាជីវកម្មនេសាទជាមួយរដ្ឋបាលជលផល។

៣. កសាងសមត្ថភាពមន្ត្រីជលផលនិងមន្ត្រីស្ថាប័នពាក់ព័ន្ធក្នុងការធ្វើជំរឿន ការបង្កើតប្រព័ន្ធគ្រប់គ្រង និងវិភាគទិន្នន័យមូលដ្ឋាន។

## ១.២. ការធ្វើជំរឿននិងផ្តល់ស្លាកលេខសម្គាល់បណ្តោះអាសន្ន

គម្រោងនេះអនុវត្តចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៨ នៅតាមតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា។ ការអនុវត្តគម្រោងនេះចែកជា៣ដំណាក់កាលៈ

### ១.២.១. ការប្រមូលព័ត៌មានបឋម

- ស្រាវជ្រាវឯកសារបង្អែកដែលពាក់ព័ន្ធនឹងការធ្វើជំរឿននិងផ្តល់ស្លាកលេខសម្គាល់នាវានេសាទសមុទ្រ
- ចុះផ្ទៀងផ្ទាត់ទិន្នន័យ និងព័ត៌មាននៅតាមតំបន់ឆ្នេរ និងរៀបចំផែនទី ទីតាំងផែ និងចំណតទូកនេសាទ
- រៀបចំបញ្ជីសំណួរដែលមានភាសាខ្មែរនិងភាសាអង់គ្លេសរួមគ្នា សម្រាប់ការធ្វើជំរឿននាវានេសាទសមុទ្រ
- រៀបចំវគ្គបណ្តុះបណ្តាល សាកល្បងប្រើបញ្ជីសំណួរ សម្រាប់ក្រុមការងារចុះធ្វើជំរឿន
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយការចាប់ផ្តើមគម្រោងនិងសំណូមពរ។

### ១.២.២. ក្រុមការងារធ្វើជំរឿននិងផ្តល់ស្លាកលេខសម្គាល់បណ្តោះអាសន្ន

១.២.២.១. ក្រុមតាមដានត្រួតពិនិត្យការធ្វើជំរឿននិងផ្តល់ស្លាកលេខសម្គាល់បណ្តោះអាសន្ន

ក្រុមតាមដានត្រួតពិនិត្យរួមមានលោក **បួយ រតនា** អនុប្រធានរដ្ឋបាលជលផល តំណាងអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ តំណាងនាយកដ្ឋានជលផលសមុទ្រ និងតំណាងក្រុមការងាររបស់សហភាពអឺរ៉ុប។

**រូបទី១. សកម្មភាពក្រុមតាមដានត្រួតពិនិត្យការធ្វើជំរឿននាវានេសាទសមុទ្រ នៅឃុំត្រពាំងរពៅ ស្រុកទឹកឈូ ខេត្តកំពត**



២.២.២. ក្រុមការងារធ្វើជំរឿននិងផ្តល់ស្លាកលេខសម្គាល់នាវានេសាទសមុទ្រ

ក្រុមការងារធ្វើជំរឿននិងផ្តល់ស្លាកលេខសម្គាល់នាវានេសាទសមុទ្រ ចែកជា២ក្រុមៈ ក្រុមធំ ធ្វើជំរឿននាវានេសាទខ្នាតធំនិងមធ្យម និងក្រុមតូច ធ្វើជំរឿននាវានេសាទខ្នាតតូច។

**ក. ក្រុមធំៈ** ក្រុមធំនីមួយៗមានមន្ត្រីចំនួន៦នាក់ ក្នុងនោះមានៈ

- មន្ត្រី២នាក់មកពីរដ្ឋបាលជលផលថ្នាក់កណ្តាលៈ ១រូបជាប្រធានក្រុម ធ្វើរបាយការណ៍សកម្មភាពនិងថតរូប (ថតរូបនាវានិងម្ចាស់នាវា)១នាក់ទៀតជាអ្នកធ្វើសម្ភាសន៍ការធ្វើនេសាទ ប្រមូលបញ្ជីសំណួរ សម្អាតកំហុស និងរក្សាទុកឯកសារ។
- មន្ត្រី២នាក់មកពីខណ្ឌរដ្ឋបាលជលផលៈ ១នាក់ជួយវាស់វែងនាវានេសាទនិងពិនិត្យម៉ាស៊ីន ១នាក់ទៀតធ្វើសម្ភាសន៍ម្ចាស់នាវានេសាទដោយប្រើប្រាស់បញ្ជីសំណួរនិងថតចម្លងឯកសារពាក់ព័ន្ធ។
- មន្ត្រី១នាក់មកពីមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត ជួយវាស់វែងនាវានេសាទនិងពិនិត្យម៉ាស៊ីន ដោយមានជំនួយពីមន្ត្រីខណ្ឌរដ្ឋបាលជលផល។
- មន្ត្រី១នាក់មកពីអាជ្ញាធរដែនដី ជួយរៀបចំនិងជូនដំណឹងទៅម្ចាស់នាវានេសាទឱ្យរៀបចំទូកនេសាទ និងឯកសារពាក់ព័ន្ធ យកមកចូលរួមក្នុងការងារប្រមូលទិន្នន័យនាវា។

ក្រុមធំត្រូវវាស់វែងនាវានេសាទ ពិនិត្យម៉ាស៊ីន និងធ្វើសម្ភាសន៍ម្ចាស់និងអ្នកបើកបរ ដោយប្រើបញ្ជីសំណួរនៅក្នុងឧបសម្ព័ន្ធទី១។ ក្រុមធំទាំងនេះត្រូវប្រមូលទិន្នន័យនិងព័ត៌មាននាវានេសាទម៉ាស៊ីនក្នុង និងមានគ្រែងដូចជា លិខិតចុះបញ្ជីនាវានេសាទ លិខិតអនុញ្ញាតឱ្យធ្វើនេសាទ សៀវភៅនាវានេសាទ និងសៀវភៅកត់ត្រាស្ថិតិ។ល។

ខ. **ក្រុមតូចៈ** ក្រុមតូចមានមន្ត្រីចំនួន២នាក់ៈ ១នាក់មកពីរដ្ឋបាលជលផលថ្នាក់កណ្តាលនិង១នាក់ទៀតមកពីខណ្ឌរដ្ឋបាលជលផលសាមី។ មន្ត្រីទាំង២នាក់នេះ ជួយគ្នាក្នុងការធ្វើសម្ភាសន៍និងវាស់វែងទូកនេសាទម៉ាស៊ីនក្នុង ឬក្រៅ ដែលគ្មានគ្រែង។ ក្រុមតូចត្រូវវាស់វែងនាវានេសាទ ពិនិត្យម៉ាស៊ីន និងធ្វើសម្ភាសន៍ដោយប្រើបញ្ជីសំណួរនៅក្នុងឧបសម្ព័ន្ធទី២។ ក្រុមតូចត្រូវប្រមូលទិន្នន័យនិងព័ត៌មាននាវានេសាទសមុទ្រម៉ាស៊ីនបាតគ្មានគ្រែង ហើយផ្តល់និងបាញ់លេខសម្គាល់ដោយប្រើលេខរបស់ក្រុមធំ។

## ១.៣. ការរៀបចំបញ្ជីសំណួរ និងឯកសារពាក់ព័ន្ធ ការផ្តល់ប័ណ្ណសម្គាល់ និងការបំពាក់ស្លាកលេខបណ្តោះអាសន្ន

### ១.៣.១. ការរៀបចំបញ្ជីសំណួរ និងឯកសារពាក់ព័ន្ធ

បញ្ជីសំណួរមានចំនួន២ដាច់ដោយឡែកពីគ្នា

**ក. បញ្ជីសំណួរទី១សម្រាប់នាវានេសាទម៉ាស៊ីនបាត និងមានគ្រែង**

បញ្ជីសំណួរទី១ត្រូវបានរៀបចំជាពីរភាសា គឺភាសាខ្មែរ និងភាសាអង់គ្លេស មាន៤ផ្នែកដូចខាងក្រោមៈ

- **ផ្នែកទី១** ព័ត៌មានទូទៅ
- **ផ្នែកទី២** លក្ខណៈសម្គាល់នាវានេសាទ
- **ផ្នែកទី៣** លិខិតអនុញ្ញាត ឧបករណ៍នេសាទ និងប្រព័ន្ធអេឡិចត្រូនិច
- **ផ្នែកទី៤** ឯកសារ (ភ្ជាប់បញ្ជីសំណួរទី១មានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ១)។

សម្រាប់នាវានេសាទម៉ាស៊ីនបាត និងមានគ្រែង ត្រូវវាស់ទំហំគ្រែង សួរអំពីលិខិតអនុញ្ញាត ការកត់ត្រាស្ថិតិ និងប្រមូលឯកសារពាក់ព័ន្ធ។

**ខ .បញ្ជីសំណួរសម្រាប់ទូកនេសាទម៉ាស៊ីនក្នុង ឬក្រៅគ្មានគ្រែង**

បញ្ជីសំណួរទី២ ត្រូវបានរៀបចំជាពីរភាសា គឺភាសាខ្មែរ និងភាសាអង់គ្លេស មាន៥ផ្នែក ដូចខាងក្រោមៈ

- **ផ្នែកទី១** ព័ត៌មានទូទៅ
- **ផ្នែកទី២** លក្ខណៈសម្គាល់នាវានេសាទ
- **ផ្នែកទី៣** ឧបករណ៍នេសាទ

- **ផ្នែកទី៤** អ្នកបើកបរនាវានេសាទ និង
- **ផ្នែកទី៥** ប្រព័ន្ធអេឡិចត្រូនិច (បញ្ជីសំណួរទី២មានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ២)។

សម្រាប់នាវានេសាទម៉ាស៊ីនក្នុង ឬក្រៅគ្មានគ្រែង គឺត្រូវវាស់វែងតែបណ្តោយ ទទឹង និងជម្រៅនាវានេសាទប៉ុណ្ណោះ។ នាវានេសាទទាំងនោះគ្មានលិខិតអនុញ្ញាត គ្មានការកត់ត្រាស្ថិតិ និងគ្មានឯកសារពាក់ព័ន្ធត្រូវប្រមូលទេ។

### ១.៣.២. ការផ្តល់ប័ណ្ណសម្គាល់នាវានេសាទនិងបំពាក់ស្លាកលេខបណ្តោះអាសន្ន

បន្ទាប់ពីធ្វើសម្ភាសន៍អ្នកនេសាទ គឺត្រូវបានផ្តល់ប័ណ្ណសម្គាល់ពណ៌ផ្ទៃមេឃសម្រាប់នាវានេសាទម៉ាស៊ីនក្រៅមានគ្រែង និងផ្តល់ប័ណ្ណសម្គាល់ពណ៌លឿងសម្រាប់ទូកនេសាទម៉ាស៊ីនក្នុង ឬក្រៅគ្មានគ្រែង។ ប័ណ្ណសម្គាល់នេះបញ្ជាក់ថា នាវានេះត្រូវបានកត់ត្រានៅក្នុងមូលដ្ឋានទិន្នន័យជាតិនិងអាចប្រើបាន នៅពេលក្រុមអធិការកិច្ចចុះត្រួតពិនិត្យ ហើយលេខដែលបានបាញ់សម្គាល់ឱ្យបានរលុប។

**រូបទី២. ប័ណ្ណសម្គាល់នាវានេសាទម៉ាស៊ីនក្នុងមានគ្រែង (ពណ៌ផ្ទៃមេឃ) និងទូកនេសាទម៉ាស៊ីនក្នុង ឬក្រៅគ្មានគ្រែង (ពណ៌លឿង)**




ស្លាកលេខសម្គាល់បណ្តោះអាសន្នមានទម្រង់ **កក៦.០០០១.ប** ដែលអក្សរ **កក** តំណាងខេត្តកោះកុង (**ក្រស** តំណាងខេត្តព្រះសីហនុ **កព** តំណាងខេត្តកំពត និង**ក** តំណាងខេត្តកែប) លេខ **៦** តំណាងនាវានេសាទ លេខ **០០០១** តំណាងលេខរៀងនាវានេសាទ និងអក្សរ **ប** តំណាងទីតាំងនាវាមានម៉ាស៊ីនបាត(**ក** ម៉ាស៊ីនក្រៅ)។

ទំហំនៃស្លាកលេខសម្គាល់ប្រែប្រួល២បែបទៅតាមទំហំនាវានេសាទ។ ស្លាកលេខសម្គាល់បណ្តោះអាសន្នសម្រាប់ខេត្តតំបន់ឆ្នេរ មានទម្រង់ដូចក្នុងតារាងទី២ ខាងក្រោម។

**តារាងទី២. ស្លាកលេខសម្គាល់បណ្តោះអាសន្នសម្រាប់ខេត្តតំបន់ឆ្នេរ**

| ខេត្តតំបន់ឆ្នេរ | ទូកនេសាទម៉ាស៊ីនបាតមានគ្រែង | ទូកនេសាទម៉ាស៊ីនក្នុង ឬក្រៅគ្មានគ្រែង |
|---|---|---|
| **កោះកុង** | កក៦.០០០១.ប | កក៦.០០០១.ក |
| **ព្រះសីហនុ** | ក្រស៦.០០០១.ប | ក្រស៦.០០០១.ក |
| **កំពត** | កព៦.០០១.ប | កព៦.០០១.ក |
| **កែប** | ក៦.០០១.ប | ក៦.០០១.ក |

គំរូស្លាកលេខនាវានេសាទសមុទ្រម៉ាស៊ីនក្នុងនិងម៉ាស៊ីនក្រៅ ត្រូវបានរៀបចំឡើងដោយបន្ទះអាលុយមីញ៉ូមដែល អាចដកនិងស៊កពុម្ពលេខ និងពុម្ពអក្សរតាមចំហៀងខាងស្តាំបាន (ចំហៀងខាងឆ្វេងកិបជាប់)។ គំរូស្លាកលេខនេះ មានពីរទំហំ ប្រើសម្រាប់នាវានេសាទខ្នាតធំនិងខ្នាតតូច។

រូបទី៣. គំរូស្លាកលេខនាវានេសាទម៉ាស៊ីនក្នុងនិងម៉ាស៊ីនក្រៅ



## ១.៤. ការជ្រើសរើសនិងការបណ្តុះបណ្តាលមន្ត្រីជំនឿន

មន្ត្រីរដ្ឋបាលជលផលចូលរួមសរុបចំនួន៣០នាក់(ស្ត្រី៦នាក់) មកពីនាយកដ្ឋានចំនួន៥ និងវិទ្យាស្ថានចំនួន ២ របស់រដ្ឋបាលជលផល មានដូចជានាយកដ្ឋានកិច្ចការរដ្ឋបាលនិងនីតិកម្ម នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ នាយកដ្ឋានអភិរក្សជលផល នាយកដ្ឋានកិច្ចការជលផល វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ និងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប (មើលបញ្ជីឈ្មោះមានជូនភ្ជាប់ជាមួយឧបសម្ព័ន្ធទី៣)។

កិច្ចការនេះចែកជា ក្រុមធំមានចំនួន១៣ក្រុម(មន្ត្រីសរុបចំនួន៧៨នាក់) ក្រុមតូចមានចំនួន២១ក្រុម (មន្ត្រីសរុបចំនួន៦៣នាក់) សរុបមន្ត្រីទាំងអស់មានចំនួន១៤១នាក់ គឺជាមន្ត្រីជលផលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ មន្ទីរសាធារណការនិងដឹកជញ្ជូន និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ។

រដ្ឋបាលជលផលបានរៀបចំវគ្គបណ្តុះបណ្តាលចំនួន២វគ្គ ដូចខាងក្រោម៖

**វគ្គបណ្តុះបណ្តាលទី១** នៅខែឧសភា ឆ្នាំ២០១៧ ដោយមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍជលផលអាស៊ីអាគ្នេយ៍សហការជាមួយរដ្ឋបាលជលផល បានរៀបចំសេចក្តីព្រាងប្រព័ន្ធទិន្នន័យ ការចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតសម្រាប់សាកល្បងនិងរៀបចំវគ្គបណ្តុះបណ្តាលមួយកាលពីថ្ងៃទី៣០ ខែសីហា ដល់ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ នៅក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ វគ្គបណ្តុះបណ្តាលនេះមានគោលបំណងដូចខាងក្រោម៖

១. ការប្រើបញ្ជីសំណួរ ការសាកសួរសិក្ខាកាមអំពីទិន្នន័យនិងព័ត៌មានដែលចាំបាច់ ការប្រើប្រព័ន្ធទិន្នន័យសម្រាប់ការចុះបញ្ជីនាវានេសាទ និងការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើនេសាទ។

២. គោលការណ៍សម្រាប់អនុវត្ត ការគ្រប់គ្រងទិន្នន័យមូលដ្ឋាន និងពាក្យបច្ចេកទេសប្រើសម្រាប់ការចុះបញ្ជីនាវានេសាទ និងផ្តល់លិខិតអនុញ្ញាតធ្វើនេសាទ។

៣. ការអនុវត្តទ្រឹស្តីនិងការធ្វើតេស្តសាកល្បងបញ្ចូលទិន្នន័យទៅក្នុងទិន្នន័យមូលដ្ឋាន។

មន្ត្រីចូលរួមសរុបមានចំនួន៤២រូប មកពីរដ្ឋបាលជលផលថ្នាក់កណ្តាល អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ ខណ្ឌរដ្ឋបាលជលផលកោះកុង ព្រះសីហនុ កំពត និងកែប ក្រសួងសាធារណការនិងដឹកជញ្ជូន មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តកោះកុង ព្រះសីហនុ កំពត និងខេត្តកែប។

ការបណ្តុះបណ្តាលនិងការសាកល្បងប្រមូលទិន្នន័យនិងព័ត៌មាននេះ ជួបបញ្ហាធំ២ គឺនាវានេសាទដែលមិនបានចុះបញ្ជី និងគ្មានលិខិតអនុញ្ញាតមិនអាចបញ្ចូលនៅក្នុងទិន្នន័យមូលដ្ឋាននេះបានឡើយ និងការធ្វើចំណាត់ថ្នាក់នាវានេសាទ គឺយោងតាមក្រុមកម្លាំងសេះរបស់នាវានេសាទ មិនមែនតាមប្រវែងនាវានេសាទដែលកំពុងកែសម្រួលឡើងវិញនៅក្នុងច្បាប់ស្តីពីជលផលឡើយ។

**រូបទី៤. វគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តជាក់ស្តែងនូវប្រព័ន្ធទិន្នន័យនៃការចុះបញ្ជីនិងផ្តល់លិខិតអនុញ្ញាតសាកល្បង**



**វគ្គបណ្តុះបណ្តាលទី២** បន្ទាប់ពីរៀបចំវិធីសាស្ត្រប្រមូលទិន្នន័យ និងព័ត៌មាននាវានេសាទសមុទ្រ និងបញ្ជីសំណួរឡើងវិញ ដើម្បីប្រមូលទិន្នន័យ កត់ត្រា វាស់ទំហំ និងចំនួននាវានេសាទមានម៉ាស៊ីនទាំងអស់ វគ្គបណ្តុះបណ្តាលលើកទី២ស្តីពីវិធីសាស្ត្រក្នុងការធ្វើជំរឿននាវានេសាទសមុទ្រ និងការសាកល្បងប្រើបញ្ជីសំណួរត្រូវបាន រៀបចំឡើងកាលពីថ្ងៃទី៣ដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៨ នៅសណ្ឋាគារឆ្នេរថ្មី ក្រុងព្រះសីហនុ។

វគ្គបណ្តុះបណ្តាលនេះមានគោលបំណង២យ៉ាង គឺបង្ហាញអំពីវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ និងការសាកល្បងប្រើបញ្ជីសំណួរក្នុងការធ្វើជំរឿនដល់ក្រុមការងារ និងធ្វើបច្ចុប្បន្នភាពទិន្នន័យនិងព័ត៌មាននាវានេសាទ ការបែងចែកក្រុមការងារ និងការដាក់លេខសម្គាល់បណ្តោះអាសន្នដល់នាវានេសាទសមុទ្រ។

មន្ត្រីចូលរួមសរុបមានចំនួន៦៥នាក់ មកពីរដ្ឋបាលជលផលថ្នាក់កណ្តាល អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ ខណ្ឌរដ្ឋបាលជលផលកោះកុង ព្រះសីហនុ កំពត និងកែប ក្រសួងសាធារណការនិងដឹកជញ្ជូន មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តកោះកុង ព្រះសីហនុ កំពត និងខេត្តកែប។

បន្ទាប់ពីការសិក្សាស្វែងយល់អំពីវិធីសាស្ត្រនិងបញ្ជីសំណួរ អង្គប្រជុំបានឯកភាពក្នុងការបែងចែកក្រុមការងារដើម្បីធ្វើសម្ភាសន៍និងវាស់វែងទូកនេសាទ ការដាក់លេខបណ្តោះអាសន្នលើនាវានេសាទនិងនាវាពាក់ព័ន្ធនឹងការធ្វើនេសាទសមុទ្រ ការដាក់លេខកូដមន្ត្រីសម្ភាសន៍និងលេខកូដបញ្ជីសំណួរ និងបានពិភាក្សាគ្នាយ៉ាងលម្អិត អំពីបញ្ហាប្រឈមនានានៅពេលចុះអនុវត្តគម្រោង។

អង្គប្រជុំក៏បានឯកភាពគ្នាចុះអនុវត្តគម្រោងព្រមគ្នាក្នុងខេត្តកោះកុងនិងខេត្តព្រះសីហនុ បន្ទាប់មកខេត្តកំពតនិងខេត្តកែប។ នៅខេត្តកោះកុងនិងខេត្តព្រះសីហនុមានក្រុមធំ២ អនុវត្តជាមួយទូកម៉ាស៊ីនបាតនិងប្រើបញ្ជីសំណួរក្នុងឧបសម្ព័ន១ និងក្រុមតូច២ អនុវត្តជាមួយទូកម៉ាស៊ីនក្រៅនិងបញ្ជីសំណួរក្នុងឧបសម្ព័ន២ សម្រាប់ខេត្តនីមួយៗ។

ការដាក់លេខបណ្តោះអាសន្ននេះ ពីព្រោះតែមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តតំបន់ឆ្នេរ មិនអាចចេញលេខ ចុះបញ្ជីបណ្តោះអាសន្នពិតប្រាកដឱ្យបាននោះឡើយ។

អង្គប្រជុំបានសំណូមពរឱ្យមានមន្ត្រីជាន់ខ្ពស់នៃអាជ្ញាធរដែនដី ចូលរួមសហការក្នុងការធ្វើជំរឿននេះ និងសង្ឃឹមថាការធ្វើជំរឿនទូកនេសាទនៅតាមបណ្តាខេត្តតំបន់ឆ្នេរ ពិតជាអាចធ្វើទៅបានដោយជោគជ័យតាមផែនការគម្រោងរបស់រដ្ឋបាលជលផលដែលបានគ្រោងទុក។

**រូបទី៥. វគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្រ្តក្នុងការធ្វើជំរឿននាវានេសាទសមុទ្រ និងការសាកល្បងប្រើបញ្ជីសំណួរ**



## ១.៥. ការរៀបចំផ្សព្វផ្សាយនិងការងាររដ្ឋបាលមុនចាប់ផ្តើមអនុវត្តការធ្វើជំរឿន

### ១.៥.១. ការរៀបចំផ្សព្វផ្សាយមុនចាប់ផ្តើមអនុវត្តការធ្វើជំរឿន

មុនចុះអនុវត្តការធ្វើជំរឿននិងដាក់ស្លាកសម្គាល់ សិក្ខាសាលាថ្នាក់ជាតិមួយស្តីពី ការចាប់ផ្តើមដំណើរការគម្រោងការប្រមូលទិន្នន័យនិងព័ត៌មានទូកនេសាទសមុទ្រនៅក្នុងប្រទេសកម្ពុជា ត្រូវបានរៀបចំនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ នៅទីក្រុងកែប ខេត្តកែប។ សិក្ខាសាលាថ្នាក់ជាតិនេះមានគោលបំណង២យ៉ាង គឺការជូនដំណឹងដល់អ្នកចូលរួមអំពីគោលបំណង វិធីសាស្រ្ត និងដំណើរការនៃការប្រមូលទិន្នន័យនិងព័ត៌មាននាវានេសាទសមុទ្រ នៅក្នុងខេត្តតំបន់ឆ្នេរ និងការជូនដំណឹងដល់អាជ្ញាធរខេត្ត អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធដើម្បីស្នើសុំកិច្ចសហការក្នុងការអនុវត្តគម្រោងនេះ។

សិក្ខាកាមចូលរួមសរុបចំនួន៦២នាក់ ក្នុងនោះមានស្រ្តីចំនួន៨រូប គឺតំណាងមកពីប្រធាននិងអនុប្រធានគណកម្មការជាតិដឹកនាំគ្រប់គ្រង និងសម្របសម្រួលសកម្មភាពប្រយុទ្ធប្រឆាំងនឹងទប់ស្កាត់បទល្មើសនេសាទអាយយូយូ ក្រុមការងារប្រយុទ្ធប្រឆាំងនឹងការនេសាទអាយយូយូរបស់រដ្ឋបាលជលផល តំណាងអភិបាលខេត្តនៃខេត្តតំបន់ឆ្នេរ អភិបាលស្រុកជាប់តំបន់ឆ្នេរ អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ គណកម្មការជាតិលម្ហសមុទ្រ នគរបាលជើងទឹក មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរទាំង៤ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តសមុទ្រតំបន់ឆ្នេរទាំង៤ និងទីប្រឹក្សាអន្តរជាតិ។

អង្គប្រជុំបានស្តាប់របាយការណ៍ស្តីពីគោលបំណងនិងគោលដៅគម្រោង វិធីសាស្រ្ត ផែនការ ទីតាំងផែ និងកន្លែងឡើងផលនេសាទ ការបែងចែកក្រុមធ្វើសម្ភាសន៍ និងក្រុមតាមដានត្រួតពិនិត្យ។

ផែនការចុះប្រមូលទិន្នន័យនាវានេសាទមានរយៈពេល៣ខែ។ ពេលវេលានៃការប្រើប្រាស់គម្រោងថវិការបស់កម្មវិធីជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាពនិងបរិយាប័ន្ននៃអនុវិស័យជលផល មានកាលកំណត់

ដែលនឹងត្រូវបញ្ចប់ត្រឹមខែតុលា ឆ្នាំ២០១៨ និងក្រុមការងារធ្វើជំរឿននាវានេសាទ ក៏ត្រូវបានបង្កើតរួចរាល់ ហេតុនេះការចុះប្រមូលទិន្នន័យនាវានេសាទនេះនឹងចាប់ផ្តើមទៅតាមផែនការកំណត់។

ប្រសិនជារង់ចាំការបង្កើតគណៈកម្មាធិការថ្មី ប្រហែលមិនអាចចំណាយថវិការបស់គម្រោងទាន់ពេលវេលាទេ។ អង្គប្រជុំបានស្នើអាជ្ញាធរមូលដ្ឋានជួយជ្រោមជ្រែង ក្នុងការប្រមូលទិន្នន័យនាវានេសាទឱ្យទទួលបានជោគជ័យនាពេលខាងមុខ។ អង្គប្រជុំបានសម្រេចពិនិត្យឡើងវិញ នូវបញ្ជីសំណួរនិងបញ្ហាបច្ចេកទេសឱ្យបានច្បាស់មុនពេលប្រមូលទិន្នន័យក្នុងគោលបំណង ចៀសវាងការភាន់ច្រឡំក្នុងអំឡុងពេលប្រមូលទិន្នន័យ។

**រូបទី៦. សិក្ខាសាលាថ្នាក់ជាតិ «ស្តីពីការចាប់ផ្តើមដំណើរការចុះធ្វើជំរឿននាវានេសាទសមុទ្រនៅក្នុងប្រទេសកម្ពុជា»**



### ១.៥.២. ការងាររដ្ឋបាលមុនចាប់ផ្តើមអនុវត្តការធ្វើជំរឿន

ការចុះធ្វើជំរឿននាវានេសាទសមុទ្រ មានរយៈពេល២ខែ និង១៥ថ្ងៃ ដោយបានចាប់ផ្តើមពីពាក់កណ្តាលខែសីហា និងបានបញ្ចប់នៅចុងខែតុលា ឆ្នាំ២០១៨។

ប្រធានក្រុមការងារបានបញ្ជូនលិខិតស្តីពីការចុះធ្វើជំរឿនរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទៅជម្រាបជូនអភិបាលខេត្តតំបន់ឆ្នេរ និងបានចុះជួបប្រជុំជាមួយអភិបាលរងខេត្តទទួលបន្ទុកកិច្ចការជលផល ដើម្បីស្នើសុំកិច្ចសហការអន្តរាគមន៍ទៅមន្ត្រីពាក់ព័ន្ធ នៅតាមតំបន់គោលដៅនៃការអនុវត្តគម្រោង។

មន្ត្រីចូលរួមសរុបទាំងអស់មានចំនួន១៦៥នាក់ ដែលក្នុងនោះមានក្រុមរងធំចំនួន១៣ក្រុម ក្រុមរងតូចចំនួន២៩ក្រុម និងក្រុមតាមដានត្រួតពិនិត្យចំនួន១ក្រុម។

**រូបទី៧. សកម្មភាពជួបប្រជុំជាមួយថ្នាក់ដឹកនាំខេត្តតំបន់ឆ្នេរ**



## ១.៦. ការរក្សា គ្រប់គ្រង និងវិភាគទិន្នន័យនិងព័ត៌មាននាវានេសាទសមុទ្រ

អ្នកជំនាញថ្នាក់ជាតិមួយនាក់បានជួយរៀបចំប្រព័ន្ធមូលដ្ឋានទិន្នន័យជាតិ ដើម្បីរក្សាទុកនិងវិភាគទិន្នន័យនាវានេសាទសមុទ្រ។ មូលដ្ឋានទិន្នន័យនិងព័ត៌មានទូកនេសាទនេះត្រូវបានរក្សាទុកនៅរដ្ឋបាលជលផលថ្នាក់កណ្តាល អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ និងខណ្ឌរដ្ឋបាលជលផល។ មូលដ្ឋានទិន្នន័យនិងព័ត៌មាននេះ ត្រូវចែករំលែកជាមួយក្រសួងនិងមន្ទីរសាធារណការនិងដឹកជញ្ជូនផងដែរ។ មូលដ្ឋានទិន្នន័យនិងព័ត៌មាននាវានេសាទសមុទ្រនេះនឹងដាក់បង្ហោះតាមអ៊ីនធឺណែត ដោយអាចបើកពិនិត្យនិងទាញយកបានតាមរយៈលេខកូដសម្ងាត់។

ការសរសេររបាយការណ៍ ការផ្សព្វផ្សាយលទ្ធផល ការធ្វើបទបង្ហាញ និងតាមដានការអនុវត្តៈ

ក. មាតិការបាយការណ៍ត្រូវមានការយល់ព្រមរវាងរដ្ឋបាលជលផលកណ្តាលនិងក្រុមបច្ចេកទេសជលផល

ខ. របាយការណ៍ចុងក្រោយ ត្រូវបានបញ្ជូនទៅរដ្ឋបាលជលផលកណ្តាលនិងក្រុមបច្ចេកទេសជលផលដើម្បីពិនិត្យនិងអនុម័ត

គ. រៀបចំសិក្ខាសាលាថ្នាក់ជាតិនិងផ្សព្វផ្សាយលទ្ធផល

ឃ. តាមដានការចុះបញ្ជីនាវានេសាទនិងផ្តល់លិខិតអនុញ្ញាត

ង. បើកយុទ្ធនាលើកកម្ពស់ការយល់ដឹងអំពីការចុះបញ្ជីនាវានេសាទនិងការផ្តល់លិខិតអនុញ្ញាត

ច. ពិនិត្យវឌ្ឍនភាពនៃការចុះបញ្ជីនាវានិងការផ្តល់លិខិតអនុញ្ញាត នៃតាមដានត្រួតពិនិត្យសកម្មភាពនាវានេសាទ។

ផែនការសកម្មភាពនៃការធ្វើជំរឿន ការផ្តល់ប័ណ្ណសម្គាល់ និងស្លាកលេខបណ្តោះអាសន្ន មានសង្ខេបក្នុងតារាងទី៣ខាងក្រោម។

**តារាងទី៣. ផែនការសកម្មភាព**

| សកម្មភាព | ឆ្នាំ២០១៨ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **ដំណាក់កាលទី១. ការរៀបចំផ្តើមអនុវត្តគម្រោង** | | | | | | | | | | | | |
| ១. ការប្រមូលព័ត៌មានបឋម | × | × | | | | | | | | | | |
| ២. ការរៀបចំបញ្ជីសំណួរ | | × | × | | | | | | | | | |
| ៣. ការរៀបចំវគ្គបណ្តុះបណ្តាល | | | | × | | | | | | | | |
| ៤. ការរៀបចំសិក្ខាសាលាចាប់ផ្តើមគម្រោង | | | | | × | | | | | | | |
| ៥. ការរៀបចំប្រកាសរួមរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសាធារណការនិងដឹកជញ្ជូន | | | | | | × | | | | | | |
| ៦. ការរៀបចំឯកសារពាក់ព័ន្ធមុនចុះប្រមូលទិន្នន័យនិងព័ត៌មាន | | | | | | | × | | | | | |
| **ដំណាក់កាលទី២. ការចុះធ្វើជំរឿន** | | | | | | | | | | | | |
| ៧. ការចុះធ្វើជំរឿននិងដាក់ស្លាកលេខសម្គាល់ | | | | | | | | × | × | × | | |
| ៨. ការរក្សា គ្រប់គ្រង និងវិភាគទិន្នន័យនិងព័ត៌មានទូកនេសាទ | | | | | | | | × | × | × | | |
| **ដំណាក់កាលទី៣. ការសសេររបាយការណ៍និងការផ្សព្វផ្សាយ តាមដានការចុះបញ្ជីនិងលិខិតអនុញ្ញាត** | | | | | | | | | | | | |
| ៩. សសេរបញ្ចប់របាយការណ៍ | | | | | | | | | | | × | × |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១០. រៀបចំសិក្ខាសាលាផ្សព្វផ្សាយលទ្ធផល | | | | | | | | | | | × | × |
| ១១ តាមដានការចុះបញ្ជីនិងផ្តល់លិខិតអនុញ្ញាតបន្ត | | | | | | | | | | | | × |

# ជំពូកទី ២
# លទ្ធផលនៃការធ្វើជំរឿន ការផ្តល់ប័ណ្ណសម្គាល់ និងស្លាកលេខបណ្តោះអាសន្ន ដល់នាវានេសាទសមុទ្រ

## ២.១. ការវិភាគទិន្នន័យនាវាសមុទ្រសរុបដែលបានធ្វើជំរឿន

ជាលទ្ធផលនាវាសមុទ្រនៅក្នុងខេត្តតំបន់ឆ្នេរដែលបានធ្វើជំរឿន ផ្តល់ប័ណ្ណសម្គាល់ និងស្លាកលេខបណ្តោះអាសន្នមានចំនួនសរុបចំនួន ៧៨១១គ្រឿង ដែលក្នុងនោះនាវាគ្មានគ្រែងចំនួន ៥០៧៣គ្រឿង និងនាវាមានគ្រែងចំនួន ២៧៤០គ្រឿង។ នាវាដែលបានធ្វើជំរឿនរួមមាននៅខេត្តកោះកុងចំនួន ២៦២៣គ្រឿង ស្មើនឹង៥២% ខេត្តព្រះសីហនុចំនួន១២៦៣គ្រឿង ស្មើនឹង២៥% កំពតចំនួន៦៦១គ្រឿង ស្មើនឹង១៣% និងខេត្តកែបចំនួន ៥២៤គ្រឿង ស្មើនឹង១០% (មើលក្រាហ្វិកទី១និងតារាងទី៤)។

**ក្រាហ្វិកទី១. នាវានេសាទនិងនាវាពាក់ព័ន្ធនេសាទដែលបានធ្វើជំរឿនគិតជាចំនួននិងគិតជាភាគរយ**




**តារាងទី៤. ចំនួននាវាសមុទ្រដែលបានប្រមូលដោយគម្រោង**

| ល.រ. | ខេត្តតំបន់ឆ្នេរ | ចំនួននាវាសរុប | នាវាគ្មានគ្រែង | នាវាមានគ្រែង |
|---|---|---|---|---|
| ១ | កោះកុង | ៣៦៣០ | ២៦២៣ | ១០០៧ |
| ២ | ព្រះសីហនុ | ២៥៤៨ | ១២៦៣ | ១២៨៥ |
| ៣ | កំពត | ១០៣៩ | ៦៦១ | ៣៧៨ |
| ៤ | កែប | ៥៩០ | ៥២៤ | ៧០ |
| **សរុប** | | **៧៨១១** | **៥០៧៣** | **២៧៤០** |

ចំនួននាវាសមុទ្រសរុបនេះមាននាវានេសាទសរុបចំនួន៧ ៥៥២គ្រឿង និងនាវាពាក់ព័ន្ធផ្សេងៗចំនួន២៥៩គ្រឿង(តារាងទី៥)។ ចំនួននាវាសមុទ្រសរុបនេះត្រូវបានបែងចែកជា៥ប្រភេទ គឺនាវានេសាទមានចំនួន៧ ៥៥២គ្រឿង ស្មើនឹង៩៧%, នាវាដឹកផលនេសាទមានចំនួន១ ៧១គ្រឿង ស្មើនឹង២% នាវាទិញផលនេសាទមានចំនួន២០

គ្រឿង ស្មើនឹង០,៣% នាវាពាក់ព័ន្ធវារីវប្បកម្មមានចំនួន៣៣គ្រឿង ស្មើនឹង០,៤% និងនាវាផ្សេងៗមានចំនួន៣៥ គ្រឿង ស្មើនឹង០,៤% (តារាងទី៦)។

**តារាងទី៥. ចំនួននាវានេសាទនិងនាវាពាក់ព័ន្ធផ្សេងៗសរុប**

| ប្រភេទនាវា | ចំនួនសរុប |
|---|---|
| នាវានេសាទ | ៧៥៥២ |
| នាវាពាក់ព័ន្ធនឹងការធ្វើនេសាទ | ២៥៩ |
| **ចំនួនសរុប** | **៧៨១១** |

**តារាងទី៦. ចំនួននិងប្រភេទនាវាសមុទ្រដែលបានធ្វើជំរឿន**

| ប្រភេទនាវាសមុទ្រ | កោះកុង | ព្រះសីហនុ | កំពត | កែប | សរុប |
|---|---|---|---|---|---|
| **នាវានេសាទ** | **៣៣៩៦** | **២៥២៣** | **១០៣៩** | **៥៩៤** | **៧៥៥២** |
| នាវាដឹកផលនេសាទ | ១៥៥ | ១៦ | ០ | ០ | ១៧១ |
| នាវាទិញផលនេសាទ | ១៤ | ៦ | ០ | ០ | ២០ |
| នាវាពាក់ព័ន្ធវារីវប្បកម្ម | ៣៣ | ០ | ០ | ០ | ៣៣ |
| នាវាផ្សេងៗ | ៣២ | ៣ | ០ | ០ | ៣៥ |
| **សរុបនាវាពាក់ព័ន្ធផ្សេងៗ** | **២៣៤** | **២៥** | **០** | **០** | **២៥៩** |
| **សរុបរួម** | **៣៦៣០** | **២៥៤៨** | **១០៣៩** | **៥៩៤** | **៧៨១១** |

## ២.២. ការវិភាគទិន្នន័យនាវានេសាទសមុទ្រសរុបដែលបានធ្វើជំរឿន

ចំនួននាវានេសាទសមុទ្រសរុបនេះមាននាវានេសាទសរុបចំនួន៧ ៥៥២គ្រឿង ក្នុងនោះខេត្តកោះកុងចំនួន ៣ ៣៩៦គ្រឿង ស្មើនឹង៤៥% ព្រះសីហនុចំនួន២ ៥២៣គ្រឿង ស្មើនឹង៣៣,៤% កំពតចំនួន១ ០៣៩គ្រឿង ស្មើនឹង ១៣,៨% និងខេត្តកែបចំនួន៥៩៤គ្រឿង ស្មើនឹង៧,៩%(តារាងទី៧)។

**តារាងទី៧. ចំនួននាវានេសាទសមុទ្រដែលបានធ្វើជំរឿននៅតាមបណ្តាខេត្តតំបន់ឆ្នេរ**

| ល.រ. | ខេត្តតំបន់ឆ្នេរ | ចំនួននាវានេសាទសមុទ្រ | ចំនួននាវានេសាទសមុទ្រគិតជា% |
|---|---|---|---|
| ១ | កោះកុង | ៣៣៩៦ | ៤៥,០ |
| ២ | ព្រះសីហនុ | ២៥២៣ | ៣៣,៤ |
| ៣ | កំពត | ១០៣៩ | ១៣,៨ |
| ៤ | កែប | ៥៩៤ | ៧,៩ |
| សរុប | | **៧៥៥២** | **១០០** |

### ២.២.១. ការធ្វើចំណាត់ថ្នាក់នាវានេសាទសមុទ្រ

#### ២.២.១.១. ការធ្វើចំណាត់ថ្នាក់នាវានេសាទសមុទ្រតាមប្រវែងបណ្តោយនាវា

ជម្រើសទី១. ការចាត់ជា៣ថ្នាក់តាមប្រវែងបណ្តោយសរុប

**តារាងទី៨. ការចាត់ថ្នាក់នាវានេសាទសមុទ្រជា៣ក្រុមតាមប្រវែងបណ្តោយសរុប នៅខេត្តតំបន់ឆ្នេរ**

| ការចាត់ថ្នាក់តាមប្រវែងនាវា(ម៉ែត្រ) | កោះកុង | ព្រះសីហនុ | កំពត | កែប | សរុប |
|---|---|---|---|---|---|
| ≥ ២៤ | ១០ | ០ | ០ | ០ | **១០** |

| | | | | | |
|---|---|---|---|---|---|
| ១២ ≤ ២៤ | ៧៧៣ | ៩៣០ | ៣១៧ | ៣០៤ | **២៣២៤** |
| < ១២ | ២៦១៣ | ១៥៩៣ | ៧២២ | ២៩០ | **៥២១៨** |
| **សរុប** | **៣៣៩៦** | **២៥២៣** | **១០៣៩** | **៥៩៤** | **៧៥៥២** |

ជម្រើសទី២. ការចាត់ជា៥ថ្នាក់តាមប្រវែងបណ្ដោយសរុប

តារាងទី៩. ការចាត់ថ្នាក់នាវានេសាទសមុទ្រជា៥ក្រុមតាមប្រវែងបណ្ដោយសរុប នៅខេត្តតំបន់ឆ្នេរ

| ការចាត់ថ្នាក់តាមប្រវែងនាវា (ម៉ែត្រ) | កោះកុង | ព្រះសីហនុ | កំពត | កែប | សរុប |
|---|---|---|---|---|---|
| ≥ ២៤ | ១០ | ០ | ០ | ០ | ១០ |
| ១៨ ≤ ២៤ | ៦៧ | ៤២ | ៦ | ០ | ១១៥ |
| ១២ ≤ ១៨ | ៧០៦ | ៨៨៨ | ៣១១ | ៣០៤ | ២២០៩ |
| ៦ ≤ ១២ | ១៧២៧ | ១៥៥៩ | ៧១៨ | ២៩០ | ៤២៩៤ |
| < ៦ | ៨៨៦ | ៣៤ | ៤ | ០ | ៩២៤ |
| **សរុប** | **៣៣៩៦** | **២៥២៣** | **១០៣៩** | **៥៩៤** | **៧៥៥២** |

ក្រាហ្វិកទី២. នាវានេសាទសមុទ្រសរុបនិងនាវានេសាទសមុទ្រ ចែកជា៥ក្រុមតាមប្រវែងបណ្ដោយនាវា នៅខេត្តតំបន់ឆ្នេរ















យោងតាមច្បាប់ជលផលថ្មីដែលបាននឹងកំពុងរៀបចំធ្វើវិសោធនកម្មនាវានេសាទសមុទ្រត្រូវបានធ្វើចំណាត់ថ្នាក់ជា៤ប្រភេទ។ នាវានេសាទខ្នាតធំ គឺជានាវានេសាទដែលមានប្រវែងបណ្តោយសរុបវែងជាង២៤ម៉ែត្រ នាវានេសាទ ខ្នាតមធ្យម គឺជានាវានេសាទដែលមានប្រវែងបណ្តោយសរុបចាប់ពី១២-២៤ម៉ែត្រ រួមបញ្ចូលនាវានេសាទអួនអូសនិងនាវាអូសឈ្នាងគ្រែងឈាមដែលមានប្រវែងខ្លីជាង១២ម៉ែត្រ នាវានេសាទខ្នាតតូច គឺជានាវានេសាទដែលមានប្រវែង បណ្តោយសរុបខ្លីជាង១២ម៉ែត្រ ដោយមិនរួមបញ្ចូលនាវានេសាទអួនអូសនិងនាវាអូសឈ្នាងគ្រែងឈាម និងនាវានេសាទគ្រួសារ គឺជានាវានេសាទគ្មានម៉ាស៊ីននិងប្រើឧបករណ៍នេសាទប្រពៃណី។ នាវានេសាទគ្រួសារមិនត្រូវបានធ្វើជំរឿនទេ។

នាវានេសាទអួនអូសនិងនាវានេសាទឈ្នាងអូសគ្រែងឈាម ដែលមានប្រវែងខ្លីជាង១២ម៉ែត្រសរុបមានចំនួន១ ១៨៨គ្រឿង ក្នុងនោះខេត្តកោះកុងចំនួន១៩៨គ្រឿង ព្រះសីហនុចំនួន៦១៥គ្រឿង កំពតចំនួន៣១២គ្រឿង និងខេត្តកែបចំនួន៦៣គ្រឿង។ ចំនួនលម្អិតតាមប្រភេទនាវានីមួយៗ មានបង្ហាញនៅក្នុងតារាងទី១០ខាងក្រោម។

**តារាងទី១០. នាវានេសាទអួនអូសនិងនាវានេសាទឈ្នាងអូសគ្រែងឈាមដែលមានប្រវែងខ្លីជាង១២ម៉ែត្រ**

| ប្រភេទនាវានេសាទ | កោះកុង | ព្រះសីហនុ | កំពត | កែប | សរុប |
|---|---|---|---|---|---|
| អួនអូស | ១៦៧ | ៥៧៩ | ៣១១ | ៦៣ | **១១២០** |
| ឈ្នាងអូសគ្រែងឈាម | ៣១ | ៣៦ | ១ | ០ | **៦៨** |
| **សរុប** | **១៩៨** | **៦១៥** | **៣១២** | **៦៣** | **១១៨៨** |

ការគណនាចំនួននាវានេសាទអួនអូសនិងនាវានេសាទឈ្នាងអូសគ្រែងឈាម ដែលមានប្រវែងខ្លីជាង១២ម៉ែត្រ ដោយដកចេញពីក្រុមនាវានេសាទដែលមានប្រវែងខ្លីជាង១២ម៉ែត្រ មកដាក់បញ្ចូលក្នុងក្រុមនាវានេសាទដែលមានប្រវែងវែងជាង១២ម៉ែត្រ ដែលត្រូវបានចាត់ជានាវានេសាទខ្នាតមធ្យម មានបង្ហាញក្នុងតារាងទី១១។

**តារាងទី១១. ការគណនាចំនួននាវានេសាទអួនអូសនិងនាវានេសាទឈ្នាងអូសគ្រែងឈាម ដែលមានប្រវែងខ្លីជាង១២ម៉ែត្រ**

| ប្រភេទនាវានេសាទ | ចំណាត់ថ្នាក់(ម) | កោះកុង | ព្រះសីហនុ | កំពត | កែប | សរុប |
|---|---|---|---|---|---|---|
| **នាវានេសាទខ្នាតធំ** | ≥ ២៤ | ១០ | ០ | ០ | ០ | ១០ |
| **នាវានេសាទខ្នាតមធ្យម** | **១២ ≤ ២៤** | **៩៦២** | **១៥៤៥** | **៦២៩** | **៣៦៧** | **៣៥១២** |
| | ១៨ ≤ ២៤ | ៦៧ | ៤២ | ៦ | ០ | ១១៥ |
| | ១២ ≤ ១៨ | ៧០៦ (+១៩៨) | ៨៨៨(+៦១៥) | ៣១១(+៣១២) | ៣០៤(+៦៣) | ២២០៩(+ |
| **នាវានេសាទខ្នាតតូច** | **៦ ≤ ១២** | **២៤២៤** | **៩៧៨** | **៤១០** | **២២៧** | **៤០៣០** |
| | ៦ ≤ ១២ | ១៧២៧(-១៨៩) | ១៥៥៩(-៦១៥) | ៧១៨(-៣១២) | ២៩០(-៦៣) | ៤២៩៤(- |
| | < ៦ | ៨៨៦ | ៣៤ | ៤ | ០ | ៩២៤ |
| | **សរុប** | **៣៣៩៦** | **២៥២៣** | **១០៣៩** | **៥៩៤** | **៧៥៥២** |

ការកំណត់ចំនួននាវានេសាទសរុប ដែលត្រូវបានធ្វើចំណាត់ថ្នាក់នាវានេសាទខ្នាតធំ នាវានេសាទខ្នាតមធ្យម និងនាវានេសាទខ្នាតតូច ផ្អែកតាមច្បាប់ថ្មីស្តីពីនាវានេសាទសមុទ្រ។ ដូច្នេះ នាវានេសាទសមុទ្រសរុបមានចំនួន៧ ៥៥២គ្រឿង ក្នុងនោះនាវានេសាទខ្នាតធំចំនួន១០គ្រឿង ស្មើនឹង០,១% នាវានេសាទខ្នាតមធ្យមចំនួន៣ ៥១២គ្រឿង ស្មើនឹង៤៦,៤% និងខ្នាតតូចចំនួន៤ ០៣០គ្រឿង ស្មើនឹង៥៣,៥% មានបង្ហាញនៅក្នុងតារាងទី១២។ ចំនួននាវានេសាទសមុទ្រដែលបានបែងចែកជា៣ខ្នាតលម្អិតតាមខេត្តតំបន់ឆ្នេរនីមួយៗ មាននៅក្នុងតារាងទី៩ខាងក្រោម។

**តារាងទី១២. ចំនួននាវានេសាទខ្នាតធំ ខ្នាតមធ្យម និងខ្នាតតូចសរុបផ្អែកតាមច្បាប់ថ្មីស្តីពីនាវានេសាទសមុទ្រ**

| ប្រភេទនាវានេសាទ | ចំណាត់ថ្នាក់ | កោះកុង | ព្រះសីហ | កំពត | កែប | សរុប |
|---|---|---|---|---|---|---|
| នាវានេសាទខ្នាតធំ | ≥២៤ | ១០ | ០ | ០ | ០ | ១០ |
| នាវានេសាទខ្នាតមធ្យម | ១២ ≤ ២៤ | ៩៦២ | ១៥៤៥ | ៦២៩ | ៣៦៧ | ៣៥១២ |
| នាវានេសាទខ្នាតតូច | < ១២ | ២៤២៤ | ៩៧៨ | ៤១០ | ២២៧ | ៤០៣០ |
| **សរុប** | | **៣៣៩៦** | **២៥២៣** | **១០៣៩** | **៥៩៤** | **៧៥៥២** |

### ២.២.១.២. ការធ្វើចំណាត់ថ្នាក់នាវានេសាទសមុទ្រតាមកម្លាំងម៉ាស៊ីនសរុប

ការធ្វើចំណាត់ថ្នាក់នាវានេសាទជា៥ថ្នាក់ផ្អែកតាមកម្លាំងម៉ាស៊ីន។ នាវានេសាទដែលមានកម្លាំងតូចជាង៥០សេះមានចំនួន៦ ៦៩៩គ្រឿង ស្មើនឹង៨៨,៧%នៃនាវានេសាទសមុទ្រទាំងអស់ មានបង្ហាញក្នុងតារាងទី១៣។

**តារាងទី១៣. នាវានេសាទសមុទ្រធ្វើចំណាត់ថ្នាក់តាមកម្លាំងម៉ាស៊ីន**

| ចំណាត់ថ្នាក់តាមកម្លាំងម៉ាស៊ីន | ចំនួននាវានេសាទ | ចំនួននាវានេសាទគិតជា% |
|---|---|---|
| < ៥០ | **៦៦៩៩** | **៨៨,៧** |

| | | |
|---|---|---|
| ៥១-៩០ | ២៧៩ | ៣,៧ |
| ៩១-១៨០ | ៤៤០ | ៥,៨ |
| ១៨១-២៧០ | ៨៣ | ១,១ |
| ២៧១-៥៤០ | ៥១ | ០,៧ |
| **សរុប** | **៧៥៥២** | **១០០** |

នាវានេសាទដែលមានកម្លាំងតូចជាង៥០សេះ គឺជានាវានេសាទភាគច្រើននៅតាមខេត្តតំបន់ឆ្នេរ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញក្នុងតារាងទី១៤ខាងក្រោម។ នាវាភាគច្រើននេះ គឺជានាវានេសាទដែលគ្មានគ្រែង។

**តារាងទី១៤. នាវានេសាទសមុទ្រធ្វើចំណាត់ថ្នាក់តាមកម្លាំងម៉ាស៊ីនតាមខេត្តតំបន់ឆ្នេរ**

| ចំណាត់ថ្នាក់តាមកម្លាំងម៉ាស៊ីន | កោះកុង | ព្រះសីហនុ | កំពត | កែប | សរុប |
|---|---|---|---|---|---|
| < ៥០ | ២៩៦៧ | ២១១៥ | ១០២៨ | ៥៨៩ | **៦៦៩៩** |
| ៥១-៩០ | ១៥៧ | ១១០ | ៧ | ៥ | **២៧៩** |
| ៩១-១៨០ | ១៧៩ | ២៥៧ | ៤ | ០ | **៤៤០** |
| ១៨១-២៧០ | ៥៧ | ២៦ | ០ | ០ | **៨៣** |
| ២៧១-៥៤០ | ៣៦ | ១៥ | ០ | ០ | **៥១** |
| **សរុប** | **៣៣៩៦** | **២៥២៣** | **១០៣៩** | **៥៩៤** | **៧៥៥២** |

របាយនៃចំណាត់ថ្នាក់នាវានេសាទសមុទ្រនៅតាមបណ្តាខេត្តតំបន់ឆ្នេរនីមួយៗ មានបង្ហាញក្នុងក្រាហ្វិកទី៣ខាងក្រោម។ នាវានេសាទនៅក្នុងខេត្ត២ គឺខេត្តកោះកុង និងខេត្តព្រះសីហនុ មានរបាយនាវានេសាទនៅគ្រប់ចំណាត់ថ្នាក់ លើកលែងតែខេត្តកំពតមាន៣ចំណាត់ថ្នាក់ និងខេត្តកែបមានតែ២ចំណាត់ថ្នាក់ប៉ុណ្ណោះ។

**ក្រាហ្វិកទី៣. នាវានេសាទសមុទ្រសរុបនិងនាវានេសាទសមុទ្រតាមខេត្តតំបន់ឆ្នេរនីមួយ បែងចែកជា៥ថ្នាក់តាមកម្លាំងម៉ាស៊ីន**















តាមការបែងចែកភារកិច្ចបណ្តោះអាសន្នរវាងរដ្ឋបាលថ្នាក់ជាតិនិងក្រោមជាតិ នាវានេសាទសមុទ្រត្រូវបានបែងចែកជា២ប្រភេទ គឺនាវានេសាទដែលមានកម្លាំងធំជាង៩០សេះនិងនាវានេសាទដែលមានកម្លាំងតូចជាង៩០សេះ។ នាវានេសាទដែលមានកម្លាំងធំជាង៩០សេះ ចំនួន៥៧៤គ្រឿង ស្មើនឹង៧,៦% និងនាវានេសាទដែលមានកម្លាំងតូចជាង៩០សេះ ចំនួន៦ ៩៧៨គ្រឿង ស្មើនឹង៩២,៤% បង្ហាញក្នុងតារាងទី១៥និងក្រាហ្វិកទី៤ខាងក្រោម។

**តារាងទី១៥. នាវានេសាទសមុទ្រធ្វើចំណាត់ថ្នាក់តាមកម្លាំងម៉ាស៊ីនតាមបណ្តាខេត្តតំបន់ឆ្នេរ**

| ចំណាត់ថ្នាក់ | ចំនួននាវានេសាទ | ចំនួននាវានេសាទគិតជា% |
|---|---|---|
| < ៩០ | ៦៩៧៨ | ៩២,៤ |
| ≥ ៩០ | ៥៧៤ | ៧,៦ |
| **សរុប** | **៧៥៥២** | **១០០** |

**ក្រាហ្វិកទី៤. នាវានេសាទសមុទ្រសរុបបែងចែកជា២ថ្នាក់ តាមកម្លាំងម៉ាស៊ីន**




ទំនាក់ទំនងរវាងប្រវែងនាវានេសាទនិងកម្លាំងសេះ បង្ហាញក្នុងក្រាហ្វិកទី៥ខាងក្រោម។ នាវានេសាទដែលមានប្រវែងខ្លីជាង១៨ម៉ែត្រមួយចំនួនធំ មានម៉ាស៊ីនតូចជាង៩0សេះ ភាគច្រើនគឺជានាវានេសាទក្រីក្រ។

**ក្រាហ្វិកទី៥. ទំនាក់ទំនងរវាងប្រវែងនាវានេសាទ និងកម្លាំងម៉ាស៊ីន**




## ២.២.២. ឧបករណ៍នេសាទសមុទ្រ

### ២.២.២.១. ឧបករណ៍នេសាទសមុទ្រប្រើនៅក្នុងដែនសមុទ្រកម្ពុជា

ឧបករណ៍នេសាទសមុទ្រ៣៤ប្រភេទ ត្រូវបានរកឃើញនៅពេលធ្វើជំរឿន។ ឧបករណ៍នេសាទសមុទ្រ ដែលកំពុងប្រើតាមលំដាប់ដូចតទៅគឺអួនអូស លបក្ដាម មងក្ដាម មងត្រី លបប្រឹស១០០ មងបង្គា សន្ទូចរនងអូសមឹក រនងខ្យងចាប់មឹកពីងពាង ឈិបយន្ត នេសាទដោយដៃ ឈ្នាងអូសគ្រែងឈាម លបត្រី សន្ទូច អួនកាកឹម លបមឹក ស្ន ផ្ទងផាង សន្ទូចរនងស្រទាប់បាត មុជជីគ្រំជីវ៉ំ(អយស្ទ័រ) អួនហ៊ំ មងបង្កងកណ្ដូប ទូកភ្លើង លបបង្គា ឈិបអូសគី ឈ្នាងដួសក្ដាម សន្ទូចរនងត្រី អួនហោះ(អួនអូសត្រី) សន្ទូចរនងបបែល ស្រទាប់បាត អួនហ៊ុមក្បែរឆ្នេរ អួនទិត មងហ៊ុម ឈ្នាងក្ដាម សំណាញ់ និងលបខ្យង។

មងត្រីត្រូវបានរួមបញ្ចូលគ្នាជាមួយមងត្រីបេកា មងត្រីកាម៉ុង មងត្រីការ៉ាវ មងត្រីក្បក មងត្រីគូន មងត្រីផ្ទោង និងមងត្រីកន្លាំង។ ប្រភេទឧបករណ៍នេសាទសមុទ្រមានចំនួន៣៤ប្រភេទ ដែលកំពុងប្រើនៅក្នុងដែននេសាទសមុទ្រ បង្ហាញក្នុងតារាងទី១៦។ ឧបករណ៍នេសាទអួនអូស គឺប្រើច្រើនបំផុតនៅក្នុងដែននេសាទសមុទ្រដែលមានចំនួនប្រមាណ២១%នៃឧបករណ៍នេសាទសរុប។

ឧបករណ៍នេសាទលបប្រឹស១០០ ស្ថិតនៅលំដាប់ទី៥ គឺជាឧបករណ៍នេសាទខុសច្បាប់(សារាចរណែនាំស្ដីពីវិធានការទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ដោយប្រើឧបករណ៍នេសាទលបកន្ទុយកណ្ដុរ ឬលបពោះវៀនជ្រូក ឬលបប្រឹស១០០ លេខ០២៧ សរណរ.កសក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)។

**តារាងទី១៦. ប្រភេទឧបករណ៍នេសាទសមុទ្រចំនួន៣៤ប្រភេទដែលកំពុងមានប្រើនៅក្នុងដែននេសាទសមុទ្រ**

| ល.រ. | ប្រភេទឧបករណ៍នេសាទ | កោះកុង | ព្រះសីហនុ | កំពត | កែប | សរុប |
|---|---|---|---|---|---|---|
| ១ | អួនអូស | ៣២៩ | ៨៥៤ | ៣២៣ | ៦៣ | ១៥៦៩ |
| ២ | លបក្ដាម | ៧៣១ | ២៣៥ | ៩១ | ១១៦ | ១១៧៣ |
| ៣ | មងក្ដាម | ៦៥១ | ២៥៩ | ២៣ | ១១៦ | ១០៤៩ |
| ៤ | មងត្រី | ៤៥៦ | ២៥៦ | ១៧៥ | ៣៧ | ៩២៤ |
| ៥ | លបប្រឹស១០០ | ១ | ២១៦ | ២៥៣ | ១៥៤ | ៦២៤ |
| ៦ | មងបង្គា | ៣៣២ | ១៨៨ | ៣០ | ៤ | ៥៥៤ |
| ៧ | សន្ទូចអូសមឹក | ២១៥ | ១២១ | ៣ | ៥១ | ៣៩០ |
| ៨ | រនងខ្សែចាប់មឹកពីងពាង | ៩៣ | ១០៣ | ៥២ | ២៣ | ២៧១ |
| ៩ | ឈិបរុញ | ៩២ | ១១២ | ៣ | ០ | ២០៧ |
| ១០ | នេសាទដោយដៃ | ៨៩ | ០ | ១៩ | ២ | ១១០ |
| ១១ | ឈ្នាងអូសគ្រែងឈាម | ៤៤ | ៥៧ | ១ | ០ | 102 |
| ១២ | លបត្រី | ៣៨ | ៣៥ | ១០ | ៥ | ៨៨ |
| ១៣ | សន្ទូចត្រី | ៦៥ | ១៤ | ១ | ០ | ៨០ |
| ១៤ | អួនកាកឹម | ៥៤ | ១ | ០ | ០ | ៥៥ |
| ១៥ | លបមឹក | ៣៧ | ៩ | ៣ | ០ | ៤៩ |
| ១៦ | ស្នួ | ៤៨ | ០ | ០ | ០ | ៤៨ |
| ១៧ | ផ្ទូងផាង | ៣ | ២៩ | ០ | ១១ | ៤៣ |
| ១៨ | សន្ទូចត្រីស្រទាប់បាត | ១៨ | ៦ | ០ | ៣ | ២៧ |
| ១៩ | មុជជីកគ្រំជីរុំ(អយស្ទ័រ) | ២ | ០ | ២៤ | ០ | ២៦ |
| ២០ | អួនហ៊ុម | ០ | ០ | ២២ | ០ | ២២ |
| ២១ | មងបង្កងកណ្ដូប | ១៨ | ០ | ០ | ០ | ១៨ |
| ២២ | នេសាទដោយប្រើភ្លើង | ១៨ | ០ | ០ | ០ | ១៨ |
| ២៣ | លបបង្គា | ០ | ១៤ | ០ | ០ | ១៤ |
| ២៤ | ឈិបរុញគី | ១៤ | ០ | ០ | ០ | ១៤ |
| ២៥ | កន្ត្រកដួសក្ដាម | ១៣ | ០ | ០ | ០ | ១៣ |
| ២៦ | សន្ទូចរនង | ១៣ | ០ | ០ | ០ | ១៣ |
| ២៧ | មងហោះ | ០ | ១១ | ០ | ០ | ១១ |
| ២៨ | សន្ទូចរនងបបែលស្រទាប់បាត | ៦ | ១ | ០ | ២ | ៩ |
| ២៩ | អួនខ្វូវ | ០ | ២ | ១ | ៥ | ៨ |

| | | | | | | |
|---|---|---|---|---|---|---|
| ៣០ | អួនទិត | ៥ | ០ | ០ | ២ | ៧ |
| ៣១ | មងហ៊ុម | ១ | ០ | ៥ | ០ | ៦ |
| ៣២ | ឈ្នាងជួសក្ដាម | ៥ | ០ | ០ | ០ | ៥ |
| ៣៣ | សំណាញ់ | ៣ | ០ | ០ | ០ | ៣ |
| ៣៤ | អន្ទាក់ខ្សែង | ២ | ០ | ០ | ០ | ២ |
| | **សរុប** | **៣៣៩៦** | **២៥២៣** | **១០៣៩** | **៥៩៤** | **៧៥៥២** |

ប្រភេទឧបករណ៍នេសាទសមុទ្រទាំងអស់ និងបែងចែកទៅតាមចំណាត់ថ្នាក់នាវានេសាទ មានបង្ហាញនៅក្នុងតារាងទី១៧ក និង១៧ខខាងក្រោម។

**តារាងទី១៧ក. ប្រភេទឧបករណ៍នេសាទសមុទ្រទាំងអស់ដែលមានប្រើនៅក្នុងដែននេសាទសមុទ្រ**

| ល.រ. | ប្រភេទឧបករណ៍នេសាទ | សរុប |
|---|---|---|
| ១ | អួនអូស | ១៥៦៩ |
| ២ | លបក្ដាម | ១១៧៣ |
| ៣ | មងក្ដាម | ១០៤៩ |
| ៤ | មងត្រី | ៩២៤ |
| ៥ | លបប្រឹស១០០ | ៦២៤ |
| ៦ | មងបង្គា | ៥៥៤ |
| ៧ | សន្ទូចអូសមឹក | ៣៩០ |
| ៨ | រនងខ្សែងចាប់មឹកពីងពាង | ២៧១ |
| ៩ | ឈិបរុញ | ២០៧ |
| ១០ | នេសាទដោយដៃ | ១១០ |
| ១១ | ឈ្នាងអូសគ្រែងឈាម | ១០២ |
| ១២ | លបត្រី | ៨៨ |
| ១៣ | សន្ទូចត្រី | ៨០ |
| ១៤ | អួនកាកឹម | ៥៥ |
| ១៥ | លបមឹក | ៤៩ |
| ១៦ | ស្នូ | ៤៨ |
| ១៧ | ផ្ទូងផាង | ៤៣ |
| ១៨ | សន្ទូចត្រីស្រទាប់បាត | ២៧ |
| ១៩ | មុជជីកគ្រំជីរុំ(អយស្ទ័រ) | ២៦ |
| ២០ | អួនហ៊ុម | ២២ |
| ២១ | មងបង្កងកណ្ដូប | ១៨ |
| ២២ | នេសាទដោយប្រើភ្លើង | ១៨ |
| ២៣ | លបបង្គា | ១៤ |
| ២៤ | ឈិបរុញគី | ១៤ |
| ២៥ | កន្ត្រកជួសក្ដាម | ១៣ |
| ២៦ | សន្ទូចរនង | ១៣ |
| ២៧ | មងហោះ | ១១ |
| ២៨ | សន្ទូចរនងបបែលស្រទាប់បាត | ៩ |
| ២៩ | អួនខ្វរ | ៨ |
| ៣០ | អួនទិត | ៧ |

| | | |
|---|---|---|
| ៣១ | មងហ៊ុម | ៦ |
| ៣២ | ឈ្នាងជួសក្តាម | ៥ |
| ៣៣ | សំណាញ់ | ៣ |
| ៣៤ | អន្ទាក់ខ្សែង | ២ |
| **សរុប** | ៧៥៥២ | |

## តារាងទី១៧ខ. ប្រភេទឧបករណ៍នេសាទសមុទ្រទាំងអស់បែងចែកទៅតាមចំណាត់ថ្នាក់នាវានេសាទ

| ល.រ. | ប្រភេទឧបករណ៍នេសាទ | >២៤ |
|---|---|---|
| ១ | អួនកាកឹម | ១០ |
| សរុប | | **១០** |

| ល.រ. | ប្រភេទឧបករណ៍នេសាទ | ១៨-២៤ |
|---|---|---|
| ១ | អួនអូស | ៥០ |
| ២ | អួនកាកឹម | ២៤ |
| ៣ | មងត្រី | ២១ |
| ៤ | លបក្តាម | ៤ |
| ៥ | រនងខ្សែងចាប់មឹកពីងពាង | ៤ |
| ៦ | លបត្រី | ៣ |
| ៧ | អួនទិត | ៣ |
| ៨ | ឈិបរុញ | 2 |
| ៩ | មងក្តាម | ២ |
| ១០ | មងបង្គា | ១ |
| ១១ | សន្ទូចអូសមឹក | ១ |
| ១២ | មងហោះ | ១ |
| សរុប | | **១១៥** |

| ល.រ. | ប្រភេទឧបករណ៍នេសាទ | ១២-១៨ |
|---|---|---|
| ១ | អួនអូស | ៣៩៩ |
| ២ | មងត្រី | ៣៤៦ |
| ៣ | លបប្រឹស១០០ | ៣១០ |
| ៤ | មងបង្គា | ២៥៨ |
| ៥ | លបក្តាម | ២២៤ |
| ៦ | មងក្តាម | ២០៤ |
| ៧ | រនងខ្សែងចាប់មឹកពីងពាង | ២០១ |
| ៨ | សន្ទូចអូសមឹក | ៥៤ |
| ៩ | លបត្រី | ៤១ |
| ១០ | ឈ្នាងអូសគ្រែងឈាម | ៣៣ |
| ១១ | ឈិបរុញ | ២៦ |
| ១២ | អួនកាកឹម | ១៤ |
| ១៣ | លបមឹក | ១៣ |
| ១៤ | មុជជីកគ្រុំជីរុំ(អេយស្ទ័រ) | ១១ |
| ១៥ | នេសាទដោយដៃ | ១០ |
| ១៦ | ផ្លូងផាង | ១០ |
| ១៧ | នេសាទដោយប្រើភ្លើង | ១០ |
| ១៨ | អួនហ៊ុម | ៧ |
| ១៩ | មងបង្កងកណ្ដប | ៧ |
| ២០ | មងហោះ | ៦ |
| ២១ | សន្ទូចត្រី | ៥ |
| ២២ | លបបង្គា | ៤ |
| ២៣ | សន្ទូចរនង | ៤ |
| ២៤ | អួនខ្សូវ | ៤ |
| ២៥ | សន្ទូចត្រីស្រទាប់បាត | ៣ |
| ២៦ | អួនទិត | ២ |
| ២៧ | ឈិបរុញគី | ១ |
| ២៨ | សន្ទូចរនងបបែលស្រទាប់បាត | ១ |
| ២៩ | អន្ទាក់ខ្សែង | ១ |
| សរុប | | **២២០៩** |

| ល.រ. | ប្រភេទឧបករណ៍នេសាទ | ៦-១២ |
|---|---|---|
| ១ | អួនអូស | ១១២០ |
| ២ | មងក្ដាម | ៧០៥ |
| ៣ | លបក្ដាម | ៤៥៥ |
